គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

# ការខារនៃការកំណត់

# ព្រំដែនដីគោក និង ព្រំដែនសមុទ្រ រវាងកម្ពុជានិងយៀកណាម

# នាឆ្នាំ១៩៧៩-២០១២

*ការផ្សាយ នៃ គណកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក*
( CFC/CBC )

ខែធ្នូ ២០១២


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

# សេចក្ដីបញ្ជាក់

*នៃ គណៈកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក*

## ចំពោះរបាយការណ៍ និង"អត្ថបទគោល" របស់រដ្ឋមន្ត្រីទី១ ហ៊ុន សែន

## អំពីបញ្ហាព្រំដែនកម្ពុជា-យៀកណាម

### ដែលបានថ្លែង នៅរដ្ឋសភា នាថ្ងៃទី៩ សីហា ២០១២

៖៖៖៖៖៖៖៖៖



c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

# សេចក្តីសង្កេតទូទៅ ៖

របាយការណ៍ អំពីបញ្ហាព្រំដែនកម្ពុជា-យៀកណាម ដែលរដ្ឋមន្ត្រីទី១ ហ៊ុន សែន បានថ្លែង នាថ្ងៃទី៩ សីហា ២០១២ នៅរដ្ឋសភា អស់រយៈពេលជាង៥ម៉ោង គ្រាន់តែជាការនិយាយប្រាជ្ញព្រោកម្តងទៀត នូវការភូតភរ អំពីច្បាប់អន្តរជាតិ ការក្រឡៃឯកសារប្រវត្តិសាស្ត្រ និងការមួលបង្កាច់អ្នកឯទៀត ដែលពួករដ្ឋមន្ត្រីរបស់ គាត់ គឺ សុខ អាន និង វ៉ា គីមហុង ជាអាទិ បានឲ្យយើងដឹង តាំងពី១០ឆ្នាំកន្លងមកហើយ ។ ហេតុដែលយើងបានឃើញច្បាស់ គឺ ក្នុងបញ្ហាព្រំដែនកម្ពុជា-យៀកណាមនេះ ហ៊ុន សែន បានសំរេចអ្វីៗទាំងអស់ ក្រោមការគាបសង្កត់ជានិច្ច នៃយៀកណាម ឬ ដោយហេតុនៃសេចក្តីល្ងីតល្ងង់ អវិជ្ជា របស់គាត់ ។

ហេតុការណ៍សំខាន់ៗ គឺ ៖

**ក-** ការគាបសង្កត់របស់យួន ទៅលើអ្នកដឹកនាំខ្មែរ នៃ«សាធារណរដ្ឋប្រជាមានិតកម្ពុជា» (ស.ប.ក.) មាន ទម្ងន់ខ្លាំងជានិច្ច តាំងពីឆ្នាំ១៩៧៩មក ដូចមានជាអាទិ គឺការទម្លាក់ចោលយ៉ាងទាន់ហន់ ពីតំណែង«រដ្ឋមន្ត្រីទី១» នៃ ហេង សំរិន, ប៉ែន សុវណ្ណ, ចាន់ ស៊ី និង«រដ្ឋមន្ត្រី»ឯទៀតៗ ដែលបានជំទាស់ (បន្តិចបន្តួច) និងនយោបាយយួន។ មេធាវីអាមេរិកាំង ឈ្មោះ អ៊ីវ៉ាន ហ្គត់សម៉ាន់[1] បានបញ្ជាក់ថា កិច្ចព្រមព្រៀងអំពីទឹកដី នៃទសវត្ស១៩៨០ ដែលហ៊ុន សែន បានចុះហត្ថលេខា ជាមួយក្រុងហាណូយ ត្រូវបានតាក់តែងឡើង ក្រោមការបង្គាប់បញ្ជា នៃពួក«អ្នកជំនាញការ »យួន នៅក្រសួងការបរទេស របស់ហ៊ុន សែន ហើយត្រូវបានគេចាត់ ទុក ជាការ«សម្ងាត់ដាច់ខាត» ។ អ៊ីវ៉ាន ហ្គត់សម៉ាន់ បានសារុបសេចក្តីថា «*នេះហើយ ជាតម្លៃថ្នូរ នៃអំណាច នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា*» ។ រីឯភាពល្ងីតល្ងង់ របស់ពួកហ៊ុន សែន វិញ គឺពួកនេះបាន សារភាពខ្លួនឯងនៅក្នុងសេចក្តីរាយការណ៍ នៃការប្រជុំនិមួយៗជានិច្ច អំពីបញ្ហាព្រំដែន ។ លុះគេបានចុះ ហត្ថលេខាលើកិច្ចព្រមព្រៀងនានាអស់ហើយ រដ្ឋមន្ត្រី គង់ សំអុល (បច្ចុប្បន្ន ឧបរដ្ឋមន្ត្រីទី១) បានធ្វើរបាយការណ៍សារុប១០ឆ្នាំ នាថ្ងៃទី១២ ធ្នូ ១៩៨៨ ដោយបានចារទុកថា ក្នុង«ការងារកំណត់ព្រំដែន» ពួកគេមាន«*កំរឹតយល់ដឹងក្នុងបច្ចេទេស នៅទាប... អ្នកបច្ចេកទេស ពិនិត្យនិងអានផែនទី*

[1] ក្នុងសៀវភៅឯកសារ របស់ អ៊ីវ៉ាន ហ្គត់សម៉ាន់ - Evan R. GOTTESMAN, *Cambodia After the Khmer Rouge. Inside the Politics of Nation building*, Yale University Press, New Haven, CT, USA, November 2002, pp 209-211.


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

*មិនសូវស៊ីជម្រៅ... គ្មានឯកសារគោល... ផែនទីសម្រាប់ផ្ទៀងផ្ទាត់និងផ្ទៃដី មិនត្រូវគ្នា... ការដាក់បង្គោលព្រំដែន ខុសចំណាំ របស់ប្រជាជន»* ។ល។ (ឯកសារ A1) ។

**ខ-** ហ៊ុន សែន មិនដែលដឹងឬយល់ អំពីគោលការណ៍ នៃច្បាប់អន្តរជាតិ ស្ដីអំពី និរន្តភាពនៃរដ្ឋទេ ហើយបានបោះបង់ចោលទាំងអស់ នូវការទាមទារ ការសំរេចចិត្ត និងការងារផ្សេងៗ របស់របបរដ្ឋខ្មែរមុនៗ ដែលជារបប**ស្របច្បាប់** ។ គាត់មិនបានមើលឃើញថា ពួកយួនហាណូយ បន្ទាប់ពីបានវាយកំទេចពួក"បនជីវ-គី" នៃសាធារណរដ្ឋយៀកណាម(ខាងត្បូង)ហើយ ក៏គេនៅតែការពារ ការទាមទារទឹកដី របស់ពួក"បនជីវ-គី"នេះ អំពីកម្ពុជា អំពីប្រទេសចិន និង អំពីប្រទេសឯទៀត ជានិច្ច ។

**គ-** ក្នុងបញ្ហានៃការកំណត់ព្រំដែន ហ៊ុន សែន បានសំអាងតែលើឯកសារ ដែលយួនយកមកប្រើ ហើយបានខឹតខំ បន្ទាបបន្ថោកតម្លៃ នៃឯកសារប្រវត្តិសាស្ត្រខ្មែរ នៃការទាមទារ ការសំរេចចិត្ត និងការប្រយុទ្ធ ដើម្បីការ-ពារបូរណភាពទឹកដី របស់រដ្ឋាភិបាលស្របច្បាប់ជាបន្តបន្ទាប់ នៃកម្ពុជា មានតាំងពីសម័យព្រះរាជាណាចក្រ ទី១ (ពីអតិតកាល មកដល់ ថ្ងៃទី១៨ មិនា ១៩៧០) សម័យសាធារណរដ្ឋខ្មែរ (ពីថ្ងៃទី១៨ មិនា ១៩៧០ ដល់ថ្ងៃទី១៧ មេសា ១៩៧៥) សម័យកម្ពុជាប្រជាធិបតេយ្យ (ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី២៣ តុលា ១៩៩១) រហូតមកដល់សម័យព្រះរាជាណាចក្រទី២ ដែលមានការទាមទារជាពិសេស របស់ព្រះបាទ នរោត្តម សីហនុ ជាព្រះមហាក្សត្រ និងជាព្រះប្រមុខរដ្ឋ ។

**ឃ-** ក្នុងបញ្ហានៃការបោះបង្គោលព្រំដែន ហ៊ុន សែន បានសម្របខ្លួន តាមការទាមទារ របស់យួនទាំងអស់ ហើយតែងតែងាកមកអះអាងថា "ខ្មែរ គ្មានបាត់បង់អ្វីទេ" ទោះបីប្រជាជនខ្មែរ បានស្រែកតវ៉ា ជាង១០ឆ្នាំមក ហើយ ថា ពួកគេត្រូវបាន ពួកទាហ៊ានព្រំដែនយួន កាត់យកដីធ្លី ផ្ទះសម្បែង វត្តអារាម ដែលគេមានតាំងពី សម័យដូន-តារបស់គេមក យ៉ាងណាក្ដី ។

**ង-** នៅទីបញ្ចប់ ហ៊ុន សែន បានខំតិះដៀល នូវ«អំពើឧក្រឹដ្ឋ» នៃអ្នកឯទៀតទាំងអស់ ក្នុងបញ្ហាព្រំដែន ជាពិសេស គាត់បានបន្ទាបបន្ថោកកិត្តិនាម នៃព្រះមហាក្សត្រ នរោត្តម សីហនុ (ដែលបានថ្កោលទោសជាដាច់ខាត ចំពោះកិច្ចព្រមព្រៀងអំពីទឹកដី នៃទសវត្ស១៩៨០នោះ) ដោយចង្អុលថា ព្រះអង្គនេះហើយ ដែលជាអ្នកបានបោះបង់មុនគេ នូវសិទ្ធិលើទឹកដីជាតិ ទៅឲ្យយួន ហើយខ្លួនគាត់ - ហ៊ុន សែន - មិនអាចធ្វើអ្វីកើត ក្រៅពីសំរេចតាមព្រះរាជឆន្ទៈ ជាបន្ទាប់ប៉ុណ្ណោះ។ ក្នុងការចោទប្រកាន់ទាំងនេះ ហ៊ុន សែន ចង់បង្ហាញ ឲ្យឃើញនាពេលនេះ នូវធម្មានុរូបភាព (ភាពត្រូវគន្លងធម៌) នៃកិច្ចព្រមព្រៀងអំពីទឹកដី ដែលគាត់បានធ្វើឲ្យយួន កាលពី៣០ឆ្នាំមុន និងដើម្បីលើកតម្កើងជាថ្មីទៀត នូវកេរ្តិ៍ឈ្មោះនៃ«សាធារណរដ្ឋប្រជាមានិតកម្ពុជា» ដែលបានកើត ពីការចូលរាតត្បាត និងការកាន់កាប់កម្ពុជា នៃកងទ័ពយួនហាណូយ ។


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

គណៈកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក (CFC/CBC) របស់យើងនេះ មិនមែនជាចលនានយោបាយ ហើយគ្មានបំណងទៅដណ្ដើមអំណាច ពីនរណាទេ ។ គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើង ដោយអតីតឥស្សរជនជាន់ខ្ពស់ខ្មែរ ទាំងស៊ីវិលទាំងទាហ៊ាន នៃអតីតរដ្ឋាភិបាលផ្សេងៗ នៃកម្ពុជា រួមជាមួយពួកបញ្ញាជន[2] ដែលបានផ្ដល់ឯកសារ និងសក្ខីភាពសំខាន់ៗជាច្រើន នៅក្នុងគោលបំណងមួយច្បាស់ គឺ ផ្ដល់ជូនជនជាតិខ្មែរទាំងអស់ (មានទាំងផ្ញើរឲ្យហ៊ុន សែន ផងដែរ) ឲបានដឹងនូវឯកសារ និងការងារជាប្រវត្តិសាស្ត្រ ដែលគេអាចផ្ទៀងផ្ទាត់បាន អំពីបូរណភាពទឹកដី ឯករាជ្យ និងឯកភាពជាតិ នៃប្រទេសកម្ពុជា ។ ហេតុនេះ យើងត្រូវជូនបងប្អូនជ្រាបនូវសេចក្ដីបញ្ជាក់មួយចំនួនទៀត ចំពោះការប្រកាសផ្ដេសផ្ដាស់ របស់ហ៊ុន សែន អំពីបញ្ហាព្រំដែនរវាងកម្ពុជានិងយៀកណាម ។

ជាបឋម ហ៊ុន សែន និងពួករដ្ឋមន្ត្រីរបស់គាត់ គួរតែអានសិក្សា នូវឯកសារនិងការវិភាគ យ៉ាងត្រឹមត្រូវបំផុត របស់អ្នកនិតិសាស្ត្រខ្មែរ សារិន ឆាក[3] អំពីបញ្ហានេះ ដែលបារាំងអាណានិគមនិយម បានបន្សល់ទុកឲ្យមក ។ លោកសារិន ឆាក បានធ្វើកំណត់សំខាន់មួយ ថា៖ «*(ក្នុងការកំណត់ព្រំដែន) បើគេប្រៀបធៀប ទៅនិងពួកអតីតប្រទេសនៃឥណ្ឌូចិន គឺថា ដែនអាណានិគមកូសាំងស៊ីន, ប្រទេសអាណ្ណាម ដែលចេះតែបុករុកនិងទាមទារ ឥតស្រាកស្រាន្ត និងប្រទេសឡាវ ដែលបារាំងបានបង្កើតជាថ្មីនោះ គេឃើញថាកម្ពុជា ដែលមិនមានបញ្ហាអ្វី(ជាមួយបារាំង)សោះ វាត្រូវបានបារាំងបង្ខាតប្រយោជន៍ ជានិច្ចកាល (ឲ្យទៅប្រទេសទាំងបី នោះ)*»[4] ។

*　　*

*

[2] មានជាអាទិ គឺ លោក *ឈាន វ៉ែ, ចុន អ៊ុក, ចាយ ធុល, លឹម គ្រី, ឧត្តមសេនីយ ខ្លង សំអុល, នាង ជិនហន, ស៊ាន ប៉េងសែ, ង៉ូវ បេងអ៊ាម, សែន អឿន, ហាក់ ព្រូ, សៅ លាង, លី ហាក់ គិមតេ, អោម ឡុន* ...។

[3]លោកសារិន ឆាក ជាអ្នកនិតិសាស្ត្រ និងជាអ្នកការទូត ជាអតីតរដ្ឋមន្ត្រី នៃសម្ដេចនរោត្តម សីហនុ ដែលត្រូវខ្មែរក្រហមដាក់ ក្នុងជំរំនៅក្រុងភ្នំពេញ ។ គេបានឃើញគាត់ នៅរស់នៅឡើយ នាពេលដែលកងទ័ពយួន បានចូលដល់ក្រុងភ្នំពេញ នាថ្ងៃទី៧ មករា ១៩៧៩ ។ ប៉ុន្តែ គាត់ត្រូវបាត់ខ្លួន ជាបន្ទាប់មក ដោយប្រហែលជាត្រូវបានពួកយួនចាប់ខ្លួន ហើយបញ្ជូនទៅស្រុកយួន បាត់ដានគាត់ទៅ ។

[4] ក្នុងសៀវភៅរបស់ សារិន ឆាក ៖SARIN CHHAK, *Les Frontières du Cambodge*, Tome I, Préface du Prince Norodom Sihanouk, Paris, Dalloz, 1966, p. 14


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

# អំពីបញ្ហា ព្រំដែនដីគោក

១- ក្នុងការផ្តើមរបាយការណ៍ភ្លាម ហ៊ុន សែន បានលើកតម្លៃខ្ពស់ ចំពោះ″កិច្ចព្រមព្រៀងបន្ថែម″ នៃឆ្នាំ ២០០៥ លើកិច្ចព្រមព្រៀងអំពីទឹកដី ដែលគាត់បានស៊ីញ៉េជាមួយយួន នាឆ្នាំ១៩៨៣ ១៩៨៥ ១៩៨៨ ដើម្បីធ្វើឲ្យកិច្ចព្រមព្រៀងខុសច្បាប់ទាំងនេះ មានសំបកស្របច្បាប់វិញ ។ យើងត្រូវរំលឹកថា រដ្ឋសភា និង ព្រះបាទ នរោត្តម សីហមុនី បានផ្តល់សច្ចាប័ន ដល់″កិច្ចព្រមព្រៀងបន្ថែម″ នៃឆ្នាំ ២០០៥ ដោយធ្មេចភ្នែក គឺគ្មានបានពិនិត្យ-ពិភាក្សាជាបឋម នូវខ្លឹមសារនិងសុពលភាព នៃកិច្ចព្រមព្រៀង ឆ្នាំ១៩៨៣ ១៩៨៥ ១៩៨៨ ទេ ។ កិច្ចព្រមព្រៀងទាំងនេះ ដែលត្រូវបានសំរេច ក្នុងរយៈកាល ដែលយៀកណាមកាន់កាប់កម្ពុជា ត្រូវចាត់ទុកជាមោឃៈទាំងអស់ ពីព្រោះជាការប្រព្រឹត្ត ផ្ទុយនិងអនុសញ្ញា នៃទីក្រុងវីយែន (Vienne) ឆ្នាំ១៩៦៩ ស្តីអំពីច្បាប់នៃសន្ធិសញ្ញាអន្តរជាតិ (ដែលកម្ពុជា បានចុះហត្ថលេខាដែរ)។ នាឆ្នាំ២០០៥នោះសោត ហ៊ុន សែន បានប្រកាសគំរាមកំហែង ជាសាធារណៈ ទៅលើអ្នកណាទាំងអស់ ដែលជំទាស់និង″កិច្ចព្រមព្រៀងបន្ថែម″ហ្នឹង មានការគំរាមសម្លាប់, ការចាប់ដាក់គុក ដោយឥតជំនុំជំរះ, ជាមួយនិងការគំរាម រំលាយរបបរាជាធិបតេយ្យ ហើយដាក់របបសាធារណរដ្ឋមកជំនួស បើព្រះមហាក្សត្រមិនព្រមចុះស៊ីញ៉េដែរទេ[5]។ ការបង្ខិតបង្ខំរបស់ហ៊ុន សែន ទៅលើ ពួកអ្នកតំណាងជាន់ខ្ពស់នៃរដ្ឋនេះ ក៏ជាបុព្វហេតុមួយទៀត នៃមោឃភាព នៃ″កិច្ចព្រមព្រៀងបន្ថែម″ ត្បិតវាផ្ទុយនិងគោលការណ៍ទូទៅនៃច្បាប់ ហើយមាត្រា៥១ នៃអនុសញ្ញានៃទីក្រុងវីយែន ឆ្នាំ១៩៦៩ ក៏បានលើកគោលការណ៍ហ្នឹង មកចែងដែរ ។

២- ហ៊ុន សែន បានប្រកាសថា «ករណីយកិច្ចនិងកាតព្វកិច្ច នៃកិច្ចការពារអធិបតេយ្យ និងបូរណភាពទឹកដី គឺជាសិទ្ធិនិងជាករណីយកិច្ច របស់ពលរដ្ឋទាំងអស់គ្នា» ។ នេះគឺហ៊ុន សែន ភរ !។ ដូចយើងបានឃើញខាងលើហើយ អំពីការគំរាមបង្ក្រាបរបស់គាត់ ចំពោះនរណា ដែលចង់ដោះស្រាយបញ្ហាហ្នឹង ឲ្យស្របតាមច្បាប់។ តាំងពីដំបូងមក (ទសវត្ស ១៩៨០) យួននិងហ៊ុន សែន មិនឲ្យពលរដ្ឋខ្មែរ បានដឹង បានឃើញ ឬ បានបញ្ចេញយោបល់អ្វី អំពីបញ្ហាព្រំដែនទេ[6] ។ ក្នុងការបោះ

---

[5] ក្នុងអត្ថបទ ៖ *Le Point sur la situation politique et sociale du 1er septembre au 31 Octobre 2005*, Bulletin EDA N° 429 http://eglasie.mepasie.org/asie-du-sud-est/cambodge/le-point-sur-la-situation-politique-et-sociale-du-36 ; និងការផ្សាយ នៃវិទ្យុ សម្លេងសហរដ្ឋអាមេរិក (VOA) ថ្ងៃទី១៧ តុលា ២០០៥។

[6] . លិខិតមួយ លេខ២៦៣ ល.ស នៃខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី (នៃ ស.ប.ក.) ចុះថ្ងៃទី២១ មេសា ១៩៨៦ ស៊ីញ៉េដោយ អនុរដ្ឋមន្ត្រី ម្យាស់-លាស់ បានឲ្យដឹងថា ការថតយកព័ត៌មាន អំពីពីធីសម្ពោធបង្គោលព្រំដែនទី១



c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

បង្គោលព្រំដែនជាក់ស្តែង ពីឆ្នាំ២០០០ មកពេលនេះ ហ៊ុន សែន តែងតែបដិសេធ ឬថ្កោលទោស ការជំទាស់ឥតគណនា របស់ប្រជាពលរដ្ឋ នៃតំបន់ព្រំដែន ប្រឆាំងនិងពួកទាហ៊ានយួន ដែលចូលមកកាត់យកដីធ្លី មកហាមមិនឲ្យធ្វើដំណាំ និងមកកំទេចឧបករណ៍ការងារ របស់គេ ជាហេតុធ្វើឲ្យកើតមានចលាចល និងការឈឺចាប់ជាខ្លាំងណាស់ ដល់ប្រជាពលរដ្ឋទាំងអស់នោះ។ រឿងទាំងនេះ បានកើតឡើង ជាពិសេស នៅខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ និងកំពត ដែល ប្រជាពលរដ្ឋបានថ្លែងថា យួនបានបង្ខិតព្រំដែន ចូលមកក្នុងទឹកដីខ្មែរ ពី៤០០-៥០០ម៉ែត្រ ដល់៥-៦គ.ម. ឬក៏ដល់១៥គ.ម.ផង នៅក្នុងខេត្តឯទៀត ។ ជាមួយគ្នានេះ ហ៊ុន សែន និងពួកទាហ៊ានយួន តែងតែហាម មិនឲអ្នកតំណាងសង្គមស៊ីវិល អ្នកតំណាងរាស្ត្រ ព្រមទាំងព្រះមហាក្សត្រ នរោត្តម សីហនុ ផង ទៅពិនិត្យ ផ្ទៀងផ្ទាត់ លើព្រំដែនថ្មីនោះឡើយ ។

ជាមួយគ្នានេះដែរ កែ គឹមយ៉ាន ដែលជានាយសេនាធិការ នៃកងទ័ព ក៏បានធ្វើរបាយការណ៍ ប្រាប់ហ៊ុន សែន អំពីការបង្ខិតព្រំដែន របស់យួន ចូលមកក្នុងទឹកដីខ្មែរ តាំងពីខែសីហា ១៩៩៩ម្លេះ (ឯកសារ *A2)។ ពីឆ្នាំ២០០១ រហូតមកនេះ ម៉ម សូណង់ដូ[7] និងពលរដ្ឋខ្មែរជាច្រើនទៀត ក៏បានថ្លែងជាសាធារណៈ អំពីការឈឺចាប់របស់ប្រជាពលរដ្ឋ នៅតាមព្រំដែនជាមួយយួន។ តាំងពីខែឧសភា ២០០២មក គណកម្មាធិការព្រំដែនកម្ពុជាយើង បានធ្វើបណ្តឹងជាបន្តបន្ទាប់ ទៅអង្គការសហប្រជាជាតិ និងទៅសហប្រធាន នៃកិច្ចព្រមព្រៀង នៅទីក្រុងប៉ារីស ស្តីពីកម្ពុជា ឆ្នាំ១៩៩១ ស្នើរឲ្យគេលុបចោល រាល់កិច្ចព្រមព្រៀងអំពីទឹកដី ដែលបានធ្វើ ដោយមិនស្មើភាពគ្នា និងខុសច្បាប់អន្តរជាតិ រវាងយៀកណាម និង ស.ប.ក. នាទសវត្ស១៩៨០[8]។ នាឆ្នាំ ២០០៥ ព្រះមហាក្សត្រនរោត្តម សីហនុ ក៏បានធ្វើចំណារលើអត្ថបទមួយ នៃសារព័ត៌មាន«កាំបូត ស្វ័រ»(Cambodge Soir) អំពីការរានទន្ទ្រានរបស់យួន មកលើខ្មែរ ថា«*ការស៊ីកកេរ(របស់យួន)នៃទឹកដីខ្មែរ នៅតែបន្តជានិច្ច... ប្រជារាស្ត្រតូចតាចយើង រងការលំបាកវេទនាខ្លាំងណាស់... តែបច្ចុប្បន្ននេះ ខ្ញុំធ្វើអ្វីមិនកើត ទេ...*»(ឯកសារ *A3)។ ទាំងអស់នេះហើយ ដែលហ៊ុន សែន មិនយល់ថាប្រជាពលរដ្ឋខ្មែរ បានគិតគូរ ការពារបូរណភាពទឹកដី នៃមាតុភូមិរបស់ខ្លួនជានិច្ច ទេ ។

៣- ហ៊ុន សែន បានថ្លែងថា ព្រំដែនដីគោក ដែលបារាំងអាណានិគម បានបន្សល់ពីឆ្នាំ១៩៥៣ ឲ្យកម្ពុជា-ឡាវ និងឲកម្ពុជា-យៀកណាម សុទ្ធសឹងជា«ព្រំដែនរដ្ឋបាលកិច្ច»ប៉ុណ្ណោះ ហើយមានតែ

---

«*ជាប្រវត្តិសាស្ត្រ*» នៅបារីត (ស្វាយ-រៀង) នាថ្ងៃទី២៤ មេសា ១៩៨៦ ខាងមុខ នឹងត្រូវ «*ទុកជាឯកសារ ដោយឥតផ្សព្វផ្សាយទូលាយ*»ទេ ។

[7] សំបុត្រលោក ម៉ម សូណង់ដូ មកលោក ស៊ាន ប៉េងសែ (គណកម្មាធិការព្រំដែនកម្ពុជា) ចុះថ្ងៃទី៣០ មករា ២០០១។

[8] លិខិតនិងចម្លើយទាំងអស់ រវាងគណកម្មាធិការព្រំដែនកម្ពុជាយើង និងអង្គការសហប្រជាជាតិ ហើយនិង សហប្រធាន នៃកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ស្តីពីកម្ពុជា អាចផ្ញើរជូនបាន តាមអ៊ីនទែណែត តាមសេចក្តីសុំ ។


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

ព្រំដែន រវាងកម្ពុជា និងដែនកូសាំងស៊ីនទេ ដែលជា«ព្រំដែនអន្តរជាតិ » (គឺព្រំដែន«រដ្ឋ») ។ ថានេះ មិនខុសស្រឡះទេ នៅលើផ្ទៃប្រវត្តិសាស្ត្រ ប៉ុន្តែក្នុងការអនុវត្តិន៍ ពីឆ្នាំ១៩៥៤មក តើខ្មែរ ឡាវ និង យួន បានសំរេចយ៉ាងណាដែរ ហើយ ? ។

ក្នុងសន្ធិសញ្ញាអន្តរជាតិនៃក្រុងហ្សឺណែវ ស្តីពីឥណ្ឌូចិនបារាំង នាខែកក្កដា១៩៥៤ គេបានបញ្ជាក់ច្បាស់ នូវវត្តមាន ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី នៃ«រដ្ឋ»បួន គឺប្រទេសយៀកណាម ទាំងពីរ (ខាងជើង និងខាងត្បូង) ប្រទេសឡាវ និងប្រទេសកម្ពុជា ។ ការបញ្ជាក់នេះ បានបង្កើតជាកាតព្វកិច្ច ឲ្យប្រទេសទាំងបួននេះ (ដែលបានចុះហត្ថលេខា លើសន្ធិសញ្ញាហ្នឹងដែរ) ទទួលស្គាល់ ថាព្រំដែនដីគោក ដែលបារាំងបានបន្សល់ទុកមកនោះ បានក្លាយជាព្រំដែន«រដ្ឋ» រវាងប្រទេសខ្លួន ហើយ។ ពេលនោះ កម្ពុជាបានផ្តល់ផែនទី ភូមិសាស្ត្ររបស់ខ្លួន យ៉ាងច្បាស់ប្រាកដប្រជា គ្មានតំបន់ស្រពិចស្រពឹល(«តំបន់ ស»)អ្វីទេ ឲ្យទៅ*គណៈ-កម្មការ អន្តរជាតិ ត្រួតពិនិត្យ* ការដកទ័ពបរទេស (គឺពួកយៀកមីញ) ពីកម្ពុជា តាំងពីឆ្នាំ១៩៥៤ដែរ (ឯកសារ *A4)។ អង្គការ″អ៊ុនតាក់″ (UNTAC) ក៏បានយកផែនទីភូមិសាស្ត្រនេះ មកធ្វើការដូចគ្នា បន្ទាប់ពីមានកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ឆ្នាំ ១៩៩១ ស្តីពីកម្ពុជា ។ ដល់ឆ្នាំ១៩៦៤ និង ១៩៦៧ យៀកណាមខាងជើង (តាមការប្រកាស់ របស់នាយករដ្ឋមន្ត្រី ផាម យ៉ាង ដុង) និង រណសិរ្សរំដោះជាតិយៀកណាមខាងត្បូង («យៀកកុង») ក៏បានសន្យាទទួលស្គាល់និងគោរព នូវ«បូរណភាពទឹកដីនៃកម្ពុជា ក្នុងព្រំដែនបច្ចុប្បន្ន» គឺ ថាព្រំដែន នៃឆ្នាំ១៩៥៤ នោះ ។

ប៉ុន្តែ បើយៀកណាមក្តី ឡាវក្តី ដែលមានទម្លាប់ជាន់ឈ្លី កិច្ចសន្យារបស់ខ្លួន ហើយបែរជាថា ព្រំដែនទាំងនោះ មានលក្ខណៈជាព្រំដែនរដ្ឋបាលកិច្ចវិញ ហើយវាមានការមិនច្បាស់លាស់ នៅលើ តំបន់ខ្លះនោះ ត្រូវពួកនេះព្រមសើរើបញ្ហាហ្នឹង ជាមួយកម្ពុជា ដោយចាប់ពីចំណុច ដែលបារាំងផ្តើម ធ្វើការកំណត់ព្រំដែន ពីដើមសតវត្សទី២០មក ។ ជាបឋម បើតាមការវិភាគលើឯកសារ ដោយលោក សារីន ឆាក យៀកណាមត្រូវប្រគល់ ឲ្យកម្ពុជាវិញ នូវខេត្រខ្មែរដ៏ធំ ឈ្មោះ«ដាក់ល័ក» (Darlac) (ដែលយួនបានចែកជា ខេត្រដាក់ឡាក់ និងខេត្រដាក់ណុង សព្វថ្ងៃ) ដែលនៅជាប់និងខេត្រ មណ្ឌលគីរី ហើយដែលបារាំងបានកាត់ យកទៅភ្ជាប់និង ប្រទេសអាណ្ណាម នាឆ្នាំ១៩២៩ ដោយ ប្រទេសកម្ពុជា មិនបានយល់ព្រមទេ[9] ។ រីឯប្រទេសឡាវ ក៏ត្រូវ ប្រគល់ឲកម្ពុជាវិញ នូវខេត្រ ចំប៉ាសាក់ និងខេត្រអត្តពូវ ដែលមិនដែលជារបស់ឡាវសោះ កាលមុនសម័យ បារាំងអាណានិគម ។

[9] ក្នុងសៀវភៅរបស់ សារិន ឆាក ៖SARIN CHHAK, *Les Frontières du Cambodge*, Tome I, Préface du Prince Norodom Sihanouk, Paris, Dalloz, 1966, p. 42 et suiv.


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

៤- ការបញ្ជាក់មួយទៀត គឺព្រំដែនដែលហៅថា«អន្តរជាតិ» រវាងដែនអាណានិគមបារាំង«កូសាំងស៊ីន» និងកម្ពុជានោះ បារាំងបានកំណត់ឡើង បន្ទាប់ពីបានកាត់យកស្រុកនិងឃុំខ្មែរ នៃតំបន់ តៃនីញ, ត្រាង បាង, ថាញ់ អាន ដែលនៅក្នុងខែត្រខ្មែរ កំពង់ចាមនិងស្វាយរៀង ទៅឲ្យដែនកូសាំងស៊ីន នាខែកក្កដា ១៨៧០ ដោយធ្វើអនុសញ្ញាបំពានច្បាប់មួយ ។ រឿងដូចគ្នានេះ ក៏បានកើតមានចំពោះឃុំខ្មែរជាច្រើន នៃតំបន់សព្វ ថ្ងៃ ហៅថា ឡុក នីញ, ភួក ឡៃ និង ហា ទៀង ។ ជាបន្ទាប់មកនៅពេលដែលបារាំង រំលាយអាណានិគម របស់គេ នាឆ្នាំ១៩៤៩ ដែនកូសាំងស៊ីន ក៏ត្រូវអស់វត្តមានហើយតាមការសមហេតុផល គឺដែនទឹកដីខ្មែរទាំងអស់ ដែលបារាំងបានកាត់ទៅឲ្យនោះ ត្រូវតែគេបង្វិលមកឲ្យកម្ពុជា ជាម្ចាស់ដើមវិញ។ គឺដោយមូលហេតុ ទាំងនេះហើយ ទើបកម្ពុជាបានធ្វើការទាមទារ និងការបំរុងទុក នូវទឹកដីដូនតារបស់ខ្លួន នៅអតិតកូសាំងស៊ីន តាំងពីឆ្នាំ១៩៤៩ នៅក្នុងសភានៃសហភាពបារាំង នៅទីក្រុងប៉ារីស រួចមកនៅក្នុងសន្និសិទ នៅទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ទៀត ។

នៅក្នុងសន្និសិទ នៃទីក្រុងហ្សឺណែវ លោក ទេព ផន ជាមេគណៈប្រតិភូនៃកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍ ដែលមានសេចក្តីជាអាទិថា ៖ *«កថាខ័ណ្ឌ ទី៧ ទី១១ និងទី១២ នៃកិច្ចព្រមព្រៀងចុងក្រោយ បានស្តី អំពីការគោរពបូរណភាពទឹកដី នៃយៀកណាម។ គណៈប្រតិភូនៃកម្ពុជា សូមជំរាបសន្និសិទ ឲ្យចាត់ទុកថា កថាខ័ណ្ឌទាំងនេះ មិនបានបំបាត់សិទ្ធិនិងប្រយោជន៍ដ៏ត្រឹមត្រូវ របស់កម្ពុជា ដែលកម្ពុជាអាចសំអាង ទៅលើតំបន់មួយចំនួន នៅយៀកណាមខាងត្បូង ដោយកម្ពុជាបានធ្វើការបំរុងទុក យ៉ាងប្រាកដប្រជារួចហើយ នាពេលចុះហត្ថលេខា លើសន្ធិសញ្ញាបារាំង-ខ្មែរ នាថ្ងៃទី៨ វិច្ឆិកា ១៩៤៩ ស្តីអំពីទំនាក់ទំនង រវាងប្រទេសកម្ពុជានិងប្រទេសបារាំង និងជាបន្ទាប់មកទៀត នាពេលដែលសភាបារាំង បានធ្វើច្បាប់ភ្ជាប់ដែនកូសាំងស៊ីន ទៅយៀកណាម»*... ហើយ*«ដើម្បីជាការបញ្ជាក់ លើសេចក្តីថ្លែងការណ៍នេះ គណៈប្រតិភូកម្ពុជា សូមជូនសមាជិកទាំងអស់ នៃសន្និសិទ នូវ«សារណា អំពីទឹកដីកម្ពុជា នៅយៀកណាមខាងត្បូង» (ភ្ជាប់ជាមួយនេះ)»* (ឯកសារ *A5)។

ប៉ុន្តែ ហ៊ុន សែន មិនដែលបានដឹងយល់ អំពីក្បួនខ្នាត នៃច្បាប់អន្តរជាតិទាំងនេះឡើយ ហើយគាត់គិតតែដាក់«កំហុស»លើកម្ពុជា និងលើពួកខ្មែរ ដែលចេះតែទាមទារទឹកដី របស់ឡាវ និងរបស់យៀកណាម ជា មិត្តសម្លាញ់របស់គាត់ ដោយគ្មានមូលដ្ឋានអ្វីទាំងអស់ ។

៥- ហ៊ុន សែន បានអះអាង នាថ្ងៃទី៩ សីហា ២០១២ នោះទៀត ថា កិច្ចព្រមព្រៀងអំពីទឹកដី របស់គាត់ ជាមួយក្រុងហាណូយ ចុះឆ្នាំ១៩៨៣ និង១៩៨៥ បានធ្វើឡើង ស្របតាមផែនទីនៃកម្ពុជា ដែលសម្តេច សីហនុ បានតម្កល់ទុក នៅអង្គការសហប្រជាជាតិ នាឆ្នាំ១៩៦៤ ។ ហ៊ុន សែន គួរតែសួរប្រជាជនខ្មែរ ដែលមានទីលំនៅ ជិតព្រំដែន មានជាអាទិ គឺ ហេង សំរិន (បច្ចុប្បន្ន ប្រធានរដ្ឋសភា) ថាហេតុអ្វីបានជាឥឡូវនេះ ដីធ្លី, ផ្ទះសម្បែងរបស់គេ វាទៅនៅក្នុងស្រុកយួនវិញ បើកាលពីទសវត្ស១៩៦០ វានៅក្នុងស្រុកខ្មែរទាំងស្រុង ហើយនៅឆ្ងាយពីព្រំដែនយួន ជាច្រើនគ.ម.ទៀតផង


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

។ ចំណែកឯព្រះមហាក្សត្រ សីហនុ ដែលជាព្រះប្រមុខរដ្ឋ (ពីឆ្នាំ១៩៩៣-២០០៤) ទ្រង់បានថ្កោលទោសច្បាស់ណាស់ ដល់កិច្ចព្រមព្រៀងអំពីទឹកដី នៃ ទសវត្ស១៩៨០ (របស់យួន និង ហ៊ុន សែន) ពីព្រោះវា«*ប៉ះពាល់ដល់គំនូសព្រំដែន ដីគោកនិងសមុទ្រ របស់កម្ពុជា ដែលត្រូវបានកំណត់ ពីឆ្នាំ១៩៦៣ ទៅ១៩៦៩*»... ហើយព្រះមហាក្សត្រ «*នឹងមិនឡាយព្រះហ័ស្ថ ទទួលស្គាល់កិច្ចព្រមព្រៀងទាំងនោះទេ*» (ឯកសារ *A6) ។ ជាបន្ទាប់មក ព្រះមហាក្សត្របានថ្កោសទោស វ៉ា គិមហុង ដែល «*ហ៊ានយកមកបង្ហាញខ្ញុំ នូវផែនទីក្លែងក្លាយ នៃប្រទេសយើង (កម្ពុជា) ហើយ អះអាង(ដោយករកុហក់) ថា ជាផែនទី នៃសម័យសង្គមរាស្ត្រនិយម នៃនរោត្តម សីហនុ ពីឆ្នាំ១៩៥៥ ដល់ ១៩៦៩*» (ឯកសារ *A7) ។

**៦**- ហ៊ុន សែន បានពេញចិត្តណាស់ និង"លទ្ធផលដ៏ប្រសើ" នៃការប្រើផែនទីលាយគ្នា របស់យួនដើម្បីការកំណត់ព្រំដែនដីគោក ឲ្យបាន«ច្បាស់លាស់»មែនទែន។ យើងសូមរំលឹកថា ផែនទីនៃកម្ពុជាឆ្នាំ១៩៦៤ ដែលអន្តរជាតិបានទទួលស្គាល់ហើយ[10] ត្រូវបានធ្វើឡើង ស្របតាមផែនទីខ្នាត ១/១០០០០០ នៃឆ្នាំ១៩៥៣ នៃវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង (IGN) ហើយត្រូវបានប្រើជាមូលដ្ឋាន ពីឆ្នាំ១៩៦៨ ដល់១៩៧២ នៃការធ្វើផែនទីភូគព្ភសាស្ត្រនៃកម្ពុជា ខ្នាត១/២០០០០០។ ផែនទីហ្នឹង ដូចយើងបានជំរាបខាងលើ ត្រូវបានសន្និសិទនៃទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ និងអង្គការ «អ៊ុនតាក់»ឆ្នាំ១៩៩២ ទទួលយកប្រើប្រាស់ដែរ ។ ម៉្យាងទៀត យើងបានសំគាល់ថា ក្នុងកិច្ចព្រមព្រៀងអំពីទឹកដី រវាងក្រុងហាណូយ-ហ៊ុន សែន ចុះថ្ងៃទី២០ កក្កដា ១៩៨៣ ស្តីអំពី"លក្ខន្តិក:ព្រំដែន" និងអំពី"គោលការណ៍ដោះស្រាយបញ្ហាព្រំដែន" គេមិនបាននិយាយ អំពីផែនទី"អ៊ុយ.តេ. អឹម." (UTM) របស់យួននិងអាមេរិកទេ ។ ប៉ុន្តែ គេបានយកវាមកប្រើ នៅ ក្នុង"សន្ធិសញ្ញា នៃការកំណត់ព្រំដែនរដ្ឋ" នៃថ្ងៃទី២៧ ធ្នូ ១៩៨៥ និងក្នុង"កិច្ចព្រមព្រៀងបន្ថែម"នៃខែតុលា ២០០៥ ។ ហ៊ុន សែន និងពួករដ្ឋមន្ត្រីរបស់គាត់ តែងតែលាក់បំបាំងនិងសាធារណៈជនជានិច្ច នូវការប្រើប្រាស់ផែនទីទាំងនេះ ដែលមានខ្នាត ១/៥០០០០ ពីព្រោះមាត្រា២ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានទទួលស្គាល់តែផែនទី នៃឥណ្ឌូចិនបារាំង ដែលត្រូវបានធ្វើឡើង នាចន្លោះឆ្នាំ១៩៣៣ និងឆ្នាំ១៩៥៣ និងតាមខ្នាត ១/១០០ ០០០ ប៉ុណ្ណោះ ។

ហេតុនេះ "សន្ធិសញ្ញានៃការកំណត់ព្រំដែនរដ្ឋ" នៃថ្ងៃទី២៧ ធ្នូ ១៩៨៥ ដែលប្រើវិធី "អ៊ុយ.តេ. អឹម."(UTM) បានយកផែនទី នៃអតិតឥណ្ឌូចិនបារាំង ខ្នាត១/១០០០០០ ចំនួន២៦ផ្ទាំង បូកជា

[10] នាចន្លោះឆ្នាំ១៩៦៣-១៩៦៩ ប្រទេសចំនួនជាង៣០ បានទទួលស្គាល់បូរណភាពទឹកដីនៃកម្ពុជា មានជាអាទិ ប្រទេសបារាំង, អង់គ្លេស, សហភាពសូវៀត, ចិនប្រជាមានិត, ជប៉ុន, អូស្ត្រាលី, យូហ្គោស្លាវី, កូរ៉េខាង ជើង, អេស្ប៉ីប, សេណេក្កាល់,... និង យៀកណាមខាងជើង ។


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

មួយនិងផែនទី របស់យួននិងអាមេរិក ខ្នាត១/៥០០០០ ចំនួន៤០ផ្ទាំង[11]។ ហ៊ុន សែន ត្រូវឆ្លើយប្រាប់ខ្មែរ ថាហេតុអ្វី បានជាគាត់សុខចិត្តប្រើផែនទី របស់យួននិងអាមេរិក ដែលវាមិន"អព្យាក្រឹត" សំរាប់កម្ពុជាឡើយ ។ ការពិត គឺការបូកបញ្ចូលផែនទីទាំងនេះ ដោយមិនសមហេតុផល និងមានផលអាក្រក់ ដែលជាប្រភពនៃទំនាស់ជាច្រើន (ដូចមានការតវ៉ាដ៏ត្រឹមត្រូវ នៅគ្រប់កន្លែង ពីប្រជាជនខ្មែរយើង) ក្នុងការកំណត់ខ្សែព្រំដែនលើដីគ្លី ពីព្រោះកម្ពុជាមិនអាចយកទឹកដី ពីខាង យៀកណាមទេ គឺមានតែយៀកណាមទេ ដែលយកពីកម្ពុជា នៅកន្លែងណាដែលផែនទីខ្នាត១/៥០០០០ ហុចប្រយោជន៍ឲ្យគេ ។ ឥឡូវនេះ ហ៊ុន សែន ចង់កែរដ្ឋធម្មនុញ្ញកម្ពុជាទៀតផង ដើម្បីកំរិតទឹកដីខ្មែរ ឲ្យស្របតាមខ្នាតយួននោះ ។

ក្នុងរឿងផ្ទៃក្រឡានៃកម្ពុជាវិញ ហ៊ុន សែន បានបដិសេធតួលេខ ១៨១ ០៣៥ គ.ម.ក្រឡា តែគាត់មិននិយាយថា គាត់បានវាស់នៅលើផែនទីណាមួយ ដោយមាននិយាមកាភូមិសាស្ត្រយ៉ាងម៉េចហើយទឹកដីភូមិ-ស្រុក ដែលឆ្លងពាក់ព័ន្ធគ្នា រវាងកម្ពុជា-យៀកណាម មានទំហំប៉ុន្មានទេ ។ មកទល់ថ្ងៃនេះហើយ ហ៊ុន សែន មិនបានបញ្ចេញជាសាធារណៈ នូវផែនទីភូមិសាស្ត្រថ្មី (ទោះបីមួយភាគខាងកើត) នៃកម្ពុជាទេ ។ ផ្ទុយទៅវិញ គាត់អះអាងថា គាត់មាន«ឧបករណ៍ទំនើប ដ៏វិក្រឹត» ដែលបានវាស់វែងទៅ ឃើញផ្ទៃក្រឡានៃកម្ពុជា មានដល់១៨១ ៣៣៥ គ.ម.ក្រឡា គឺ លើសផ្ទៃក្រឡាមុន ៣០០គ.ម.ក្រឡា ដោយគ្មានយកដីគ្លីអ្វី ពីយួនទេ… តែគាត់មិនបញ្ជាក់ថា វានៅត្រង់កន្លែងណាទេ។ មិនត្រឹមប៉ុណ្ណឹង ហ៊ុន សែន ធ្លាប់បានប្រកាសហើយ កាលពីខែវិច្ឆិកា ២០០៥ ថា "កិច្ចព្រមព្រៀងបន្ថែម"របស់គាត់ជាមួយយួន ដែលព្រះបាទសីហមុនី ត្រូវស៊ីញេនោះ *«នឹងធ្វើឲ្យកម្ពុជា បានចំណេញដីគ្លី និងផ្ទៃទឹក ជាច្រើនពាន់គ.ម.ក្រឡា»*[12]។ នេះ ជាការភរបោកប្រាស់ ជាធម្មតា របស់ ហ៊ុន សែន ដោយគាត់មិនដែលបង្ហាញភស្តុតាងឡើយ ។

**៧**- ហ៊ុន សែន បានថ្លែងខាងលើថា គាត់ត្រូវតែចរចាជាមួយយួន ដោយប្រើផែនទីផ្សេងៗ ដើម្បីតំរឹមតំរង់ ព្រំដែន«រដ្ឋបាលកិច្ច»មិនស្របច្បាប់ និងមិនច្បាស់លាស់ នៅលើដីគោក និងលើផ្ទៃសមុទ្រ ដែលបារាំងបានធ្វើ ទុកឲ្យ ។ រួចហើយ គាត់ប្រកាសថា ក្នុងការចរចានោះ ពួកគាត់បានអនុវត្តិ នូវ«គោលការណ៍អន្តរជាតិ»មួយ ហៅថា *«អ៊ុទី ប៉ូស៊ីដេទីស»*(*Uti possidetis*) ដែលគាត់បានយល់ (ខុស) ថាជាគោលការណ៍"**ខ្សែព្រំដែន មិនកែប្រែ**" ។ ការអះអាងច្របូកច្របល់ អំពីការចរចាទាំង

[11] ផែនទីយួន ត្រូវបានធ្វើនៅចន្លោះឆ្នាំ១៩៦០-១៩៧០ ចំណែកផែនទីអាមេរិក ត្រូវបានធ្វើ ក្នុងពេលសង្គ្រាម នៅយៀកណាម។

[12] ក្នុងអត្ថបទ ៖KONG SOTHANARITH, *Le Roi signera aujourd'hui, selon Hun Sen*, Journal Cambodge Soir, 30 novembre 2005.


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

នេះ អាចធ្វើឲអ្នកស្តាប់-អ្នកអានវឹលមុខ លែងយល់អ្វីទាំងអស់។ ពាក្យឡាតាំង «*អ៊ុទី ប៉ូស៊ីដេទីស*» (*Uti possidetis* = selon que vous possédez) មានអត្ថន័យ ថា«តាមរបស់ដែលអ្នកមានហើយ» ដោយនៅក្នុងគំនិតថា *បើអ្នកមិនមានការទាមទារ(សមហេតុផល)អ្វីទៀតទេ* ។ ដូច្នេះ ក្នុងបញ្ហាព្រំដែនរដ្ឋ វិធាន(ឬ វិធី)«*អ៊ុទី ប៉ូស៊ីដេទីស*» មិនត្រូវនិងគំនិតថាជា"ខ្សែព្រំដែន មិនកែប្រែ"ទេ (*une frontière intangible*) ដែលមានលក្ខណៈជាច្បាប់អន្តរជាតិ ហៅថា"*ហ៊្ស៊ុយ កូហ្សង់*" (*jus cogens*) ដែលជាច្បាប់បង្ខំ (un droit contraignant) ឲ្យភាគីផ្សេងៗ ទទួលស្គាល់ជាចាំបាច់ ។ ប៉ុន្តែ ហ៊ុន សែន បានបញ្ជាក់ទៀតថា វិធាន«អ៊ុទី ប៉ូស៊ីដេទីស» ត្រូវបានអនុវត្តិ ដោយប្រទេសជាច្រើន ក្នុងពិភពលោក ហើយ«*កម្ពុជា នៃសម័យព្រះករុណា នរោត្តម សីហនុ ក៏បានអនុវត្តិគោលការណ៍ហ្នឹង តាំងពីឆ្នាំ១៩៥៣ ក្នុងការកំណត់ ព្រំដែនដីគោកនិងព្រំដែនសមុទ្រ របស់ខ្លួន ជាមួយប្រទេសជិតខាង... វៀរលែងតែសាធារណរដ្ឋខ្មែរ នៃសេនាប្រមុខ លន់ នល់ ដែលបានបោះបង់ចោល ក្នុងបញ្ហាព្រំដែនសមុទ្រ នៃកម្ពុជា*» ។ សេចក្តីទាំងនេះ វាខុសស្រឡះទាំងអស់ ។

ការពិត គេអនុវត្តិ វិធាន«*អ៊ុទី ប៉ូស៊ីដេទីស*» តែក្នុងករណី ដែលគ្មានការតវ៉ា អំពីភាគីផ្សេងៗ ហើយគេបានឃើញក្នុងលោក តែក្នុងករណីមួយ គឺការកំណត់ព្រំដែន នាដើមសតវត្សទី១៩ រវាងពួកសាធារណរដ្ឋខ្លះ នៅទ្វីបអាមេរិកខាងត្បូង ដែលជាអតិតអាណានិគម នៃប្រទេសអេស្ប៉ាញ ។ គេបានប្រើ វិធីប្រហែលគ្នានេះ ដោយមិនចេញឈ្មោះ នៅប្រទេសខ្លះ នៃអង្គការឯកភាពអាហ្វ្រិក តែមិនបានពេញលេញទេ ត្បិតប្រទេសទាំងនោះ នៅមានការតវ៉ារវាងគ្នា អំពីទឹកដីជានិច្ច ។ ហេតុនេះ វិធាន«*អ៊ុទី ប៉ូស៊ីដេទីស*» មិនមែនជាគោលការណ៍មួយ នៃ«ច្បាប់អន្តរជាតិ» ដូចហ៊ុន សែន ថាស្មានៗ នោះទេ ហើយគ្មានតម្លៃជាច្បាប់ជាវិជ្ជមាន ទេ ។

ចំណុចទី២ គឺតាំងពីឆ្នាំ១៩៤៩ មក កម្ពុជាដែលបានធ្វើការបំរុងទុកជាច្រើន ក្នុងបញ្ហាទឹកដីខ្មែរជាមួយ យួន មិនដែលសរសេរក្នុងឯកសារផ្លូវការ ឬបន្លឺ អំពីវិធាន«*អ៊ុទី ប៉ូស៊ីដេទីស*»នេះទេ ហើយតែងតែធ្វើការតវ៉ា ជាបន្តបន្ទាប់ ជាផ្លូវការ ប្រឆាំងនិងបារាំង ដែលសំរេចមិនសមហេតុផលភ្ជាប់អតិតដែនកូសាំងស៊ីនទាំងមូល ទៅឲប្រទេសអាណ្ណាម (យៀកណាម) ។ ម្យ៉ាងទៀត តាមកំណត់ ពីឆ្នាំ១៩៦៤ របស់លោកសារិន ឆាក ប្រទេសឡាវនិងយៀកណាម ក៏មិនដែលបានលើកអំពីវិធាន«*អ៊ុទី ប៉ូស៊ីដេទីស*»ហ្នឹង មកសំអាងអ្វីដែរ[13] ។ ចំណែកឯជំហរ នៃសាធារណរដ្ឋខ្មែរវិញ គឺដូចគ្នាទាំងស្រុង និងជំហរនៃរបបសម្តេច នរោត្តម សីហនុ ក្នុងបញ្ហាព្រំដែនដីគោកនិងសមុទ្រ ។

[13] ក្នុងសៀវភៅរបស់ សារិន ឆាក ៖SARIN CHHAK, *Les Frontières du Cambodge*, Tome I, 1966, p. 18


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

ក្នុងបញ្ហាសមុទ្រ ផែនទីនៃខ្ពង់រាបបាតសមុទ្រខ្មែរ នៃថ្ងៃទី១ កក្កដា ១៩៧២ មិនមែនត្រូវបានធ្វើឡើង ក្នុងរយៈកាល២៤ម៉ោង ឬក៏បានធ្វើ ដោយមនុស្ស២-៣នាក់ប៉ុណ្ណោះទេ ។ ផែនទីនេះ ត្រូវបានគេផ្ដើមគិតគូរនិងធ្វើឡើង នាឆ្នាំ១៩៥៧ តាមក្រឹត្យនៃព្រះបាទ នរោត្តម សុរាម្រិទ្ធ (ឯកសារ *A8) ហើយត្រូវបានពិនិត្យ និងរៀបចំគូសជាថ្មី នាឆ្នាំ១៩៦៨ ដោយរដ្ឋាភិបាល ប៉ែន នុត ដើម្បី សំរបតាមអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៥៨ ស្ដីអំពីច្បាប់សមុទ្រ ។ កិច្ចការទាំងនេះ បានធ្វើក្រោមការណែនាំ នៃរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម នាពេលនោះ ឈ្មោះ គាត ឈន់ ដែលបន្ទាប់មក បានធ្វើជាសមាជិក នៃ «គណៈ-កម្មការបច្ចេកទេស » នៃទីស្ដីការនាយករដ្ឋមន្ត្រីផងទៀត (សព្វថ្ងៃនេះ ជាឧបនាយករដ្ឋមន្ត្រី របស់ ហ៊ុន សែន) (ឯកសារ *A9) ។

* *

*

# អំពីបញ្ហា ព្រំដែនសមុទ្រ

ហ៊ុន សែន បានថ្កោលទោសជាខ្លាំង លើផែនទីនៃខ្ពង់រាបបាតសមុទ្រខ្មែរ នៃថ្ងៃទី១ កក្កដា ១៩៧២ នេះ ថាជា«*មរតកប្រវត្តិសាស្ត្រ ដោយគ្មានការទទួលខុសត្រូវ ក្នុងស្មារតីជាតិនិយមជ្រុល នៃក្រុមអ្នកនយោបាយសាធារណរដ្ឋ ដឹកនាំដោយលន់ នល់ បានបំផុសឡើងនោះ មិនបានផ្ដល់ផលល្អអ្វី ដល់ប្រទេសជាតិនិងប្រជាជនកម្ពុជា ក្រៅពីភ្នក់ភ្លើងសង្គ្រាម និងការវិនាសហិនហោចនោះទេ*»។ នេះជាឧទាហរណ៍ នៃការនិយាយផ្ដេសផ្ដាស់ តាមតែនឹកឃើញ របស់ហ៊ុន សែន និងក្រុមគាត់ ក្នុងបញ្ហាជាតិ ។ យើងបានបង្ហាញហើយថា ថ្ងៃទី១ កក្កដា ១៩៧២ គ្រាន់តែជាថ្ងៃ ដែលសាធារណរដ្ឋខ្មែរ បានបញ្ចប់កិច្ចការបច្ចេកទេស ហើយបានផ្សព្វផ្សាយផែនទី នៃខ្ពង់រាបបាតសមុទ្រខ្មែរ ដែលត្រូវបានតាក់តែង ដោយរដ្ឋាភិបាលនៃកម្ពុជា ជាបន្តបន្ទាប់ ក្នុងរយៈកាលបួនឆ្នាំ កន្លងមកនោះ ។ អ្នកទទួលខុសត្រូវ រួមទាំងអ្នកឯកទេសខ្មែរ និងបារាំង(ដែលរដ្ឋាភិបាលបារាំងបានបញ្ជូនមក) ដែលបានចូលរួមក្នុងការងារ ក៏មាននៅរស់ខ្លះដែរ ដែលអាចធ្វើជាសាក្សី ក្នុងរឿងនេះ។ ចំណែកឯសង្គ្រាម (ទី១) នៅកម្ពុជា វាបានផ្ទុះ មុនការផ្សព្វផ្សាយផែនទីឆ្នាំ១៩៧២ហ្នឹង ។ ជនជាតិ បែលហ្សិក ឈ្មោះ រ៉ាអ៊ូល ហ្សេណារ (Raoul Jennar) ដែលហ៊ុន សែន បានចាត់តាំងជាទីប្រឹក្សានយោបាយ បានសរសេរកំណត់មួយថា ចាប់ពី«*ថ្ងៃទី២៩ មិនា ១៩៧០ កងកម្លាំងយៀកកុង និងយៀកណាមខាងជើង បានវាយប្រហារកងទ័ព នៃរដ្ឋាភិបាល (លន់ នល់)។ ជាយ៉ាងរហ័សណាស់ កងទ័ពកុម្មុយនីស្ដ៍*


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

*យៀកណាម បានពង្រីកកម្លាំងរបស់ខ្លួន ទៅដល់ខែត្រខ្មែរជាច្រើន...»*[14]។ នាពេលនោះ គេបានដឹងគ្រប់គ្នាទៀតថា កម្លាំងទ័ពខ្មែរក្រហម និងទ័ពខ្មែរសីហនុនិយម វាសឹងតែគ្មានរូបរាងផងទេ ។ រីឯការបំផ្លាញជាមហន្តរាយវិញ ពិភពលោកទាំងមូល បានដឹងហើយ ថាជាស្នារដៃរួម នៃពួកខ្មែរក្រហម (ដែល ហ៊ុន សែន ជាសកម្មជនធំម្នាក់) និងពួកយួនដែលបានលុកលុយ និងកាន់កាប់កម្ពុជា លុះត្រាតែសន្និសិទ នៅទីក្រុងប៉ារីស នាខែតុលា ១៩៩១ បានបញ្ចប់ ។

៩- ការអះអាងចម្លែកមួយទៀត របស់ហ៊ុន សែន គឺថា*«នៅឆ្នាំ១៩៦៤ កម្ពុជា(នៃសម្ដេចនរោត្ដម សីហនុ) បានយកផែនទីព្រំដែនសមុទ្រ ខ្នាត១/៣០០០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រកម្ពុជា ដែលបានយក ខ្សែប្រេវិយេ (Brévié) ឆ្នាំ១៩៣៩ កំណត់ជាព្រំដែនសមុទ្រ រវាងកម្ពុជានិងវៀតណាម ទៅតម្កល់ទុក នៅអង្គការសហប្រជាជាតិ និងបានស្នើសុំឲប្រទេសសាមី និងអន្តរជាតិ ទទួលស្គាល់ព្រំដែននេះ ថា ជាខ្សែព្រំដែនសមុទ្រ រវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម ។ កម្ពុជានាពេលនោះ ក៏ទទួលបានការគាំទ្រពីប្រទេសសាមី និងអន្តរជាតិ មួយចំនួន ដោយទទួលស្គាល់ថា ខ្សែប្រេវិយេ ជាខ្សែព្រំដែនសមុទ្រ រវាងកម្ពុជានិងវៀតណាម»*។ ជាបន្ទាប់មក ហ៊ុន សែន បានពន្យល់ថា *«ចំណុចនេះ មានន័យថា កម្ពុជា(នៃសម្ដេចនរោត្ដម សីហនុ) ឈប់ទាមទារ យកកោះត្រល់មកវិញហើយ ពីព្រោះវាជាកោះ នៅខាងត្បូងខ្សែប្រេវិយេ»* ។ ហ៊ុន សែន បានពន្យល់ទៀតថា *«លោកប្រេវិយេ បានដាក់កោះត្រល់ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង របស់វៀតណាម (កូសាំងស៊ីន) ហើយនៅឆ្នាំ១៩៤៩ កូសាំងស៊ីនត្រូវបានបារាំង ប្រគល់ទៅឲព្រះចៅបាវដាយ»* ។ ហ៊ុន សែន ខឹតខំការពារណាស់ - ទាំងងងឹតងងល់ - នូវអ្វីៗ ដែលបានទៅដល់ដៃយួនហើយ ។

ជាបឋម យើងបានដឹង(ខាងលើ)ហើយ ថា តាមកំណត់ហេតុជាផ្លូវការនានា នៃទសវត្សរ៍១៩៨០ នៃ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ការតាក់តែងកិច្ចព្រមព្រៀងទឹកដីទាំងអស់ ជាមួយយួនបានធ្វើឡើង នៅក្រោមបញ្ជាយួនទាំងស្រុង ដោយហ៊ុន សែន និងក្រុមគាត់ បានសារភាពថា ខ្លួនខ្វះឬគ្មានឯកសារ និងផែនទីភូមិសាស្ត្រត្រឹមត្រូវ សំរាប់ផ្ទៀងផ្ទាត់ទេ ។ ការណ៍ដែលយើងអាចបញ្ជាក់បានវិញ គឺ ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៧៥ នៅក្នុងរដ្ឋាភិបាលនានានិងក្នុងរដ្ឋបាលជាន់ខ្ពស់ នៃកម្ពុជា គ្មាននរណាម្នាក់បានដឹងថាមាន ផែនទីព្រំដែន**សមុទ្រ** រវាងកម្ពុជានិងយៀកណាម ត្រូវបានតម្កល់ទុក នៅអង្គការសហប្រជាជាតិ នាឆ្នាំ១៩៦៤ ឬនាឆ្នាំណាមួយទៀតឡើយ ។ ផ្ទុយទៅវិញ នាចន្លោះឆ្នាំ១៩៥៧-១៩៧៥ តាមឯកសារជាប្រវត្តិសាស្ត្រ រដ្ឋាភិបាលកម្ពុជាទាំងអស់ ***មិនដែល***ទទួលស្គាល់ថាខ្សែប្រេវិយេ ជាខ្សែព្រំដែនសមុទ្រ រវាងកម្ពុជានិងយៀកណាម(ខាងត្បូង)ឡើយ ។ នាថ្ងៃទី៧ មិថុនា **១៩៥៧** សម្ដេច នរោត្ដម សីហនុ បានធ្វើកំណត់មួយ ជាការ*"សម្ងាត់និងប្រញាប់"* ទៅឲ្យ

[14] ក្នុងសៀវភៅរបស់ រ៉ាអ៊ូល ហ្សេណារ ៖ Raoul M. JENNAR, *Les Clés du Cambodge*, Paris, Maisonneuve & Larose, 1995, p. 70.



c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

រដ្ឋមន្ត្រីក្រសួងការពារប្រទេស[15]«*ចាត់ចែងកិច្ចការពារកោះខ្មែរទាំងអស់ នៅក្នុងឈូងសមុទ្រសៀម ជាពិសេស កោះតាង កោះពូឡូវ៉ៃ និងកោះពូឡូប៉ង់យ៉ង (ក្រចកសេះ)...*»(ឯកសារ *A10) ។ ជាបន្ទាប់មក នាថ្ងៃទី៦ មេសា **១៩៦០** រដ្ឋមន្ត្រីក្រសួងការបរទេស នៃកម្ពុជា - លោកសឺន សាន - បានផ្ញើកំណត់ការទូត រំលឹកប្រាប់ទៅរដ្ឋាភិបាលយួន នៅទីក្រុងសៃហ្គុង(ព្រៃនគរ) អំពី«*អធិបតេយ្យ នៃកម្ពុជា លើកោះត្រល់... ដែលខ្សែបន្ទាត់ប្រេវិយេ មិនបានបំបាត់ចោលទេ*» (ឯកសារ *A11)។ បន្ទាប់មកទៀត នាថ្ងៃទី៤ មករា **១៩៦៤** រដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជា - លោកហួត សម្បត្តិ - បានផ្ញើ កំណត់ការទូតមួយថ្មីទៀត ទៅឲរដ្ឋាភិបាលយួនខាងត្បូង ដើម្បី«*បញ្ជាក់ជាថ្មីយ៉ាងដាច់ខាត នូវអធិបតេយ្យ នៃកម្ពុជា លើកោះនានា ដែលរដ្ឋាភិបាល នៃសាធារណរដ្ឋយៀកណាម (យៀកណាមខាងត្បូង) កំពុងកាន់កាប់ មានទាំងកោះត្រល់ផង រួមទាំងខែត្រខ្មែរទាំងឡាយ នៅកូសាំងស៊ីន...**ហើយរដ្ឋាភិបាលយើង ទាមទារឲ្យយៀកណាម បង្វិលមកឲ្យកម្ពុជាវិញ ជាចាំបាច់...***»(ឯកសារ *A12)។ ហេតុនេះ ក្នុងការងារ គាក់តែងផែនទីនៃខ្ពង់រាបបាតសមុទ្រខ្មែរ នាឆ្នាំ១៩៥៧ក្តី រួចមកនាចន្លោះឆ្នាំ**១៩៦៨**និង**១៩៧២**ក្តី អ្នកទទួលខុសត្រូវខ្មែរទាំងអស់ បានប្រកាន់ជំហរនេះ ដូចៗគ្នា ។ លុះដល់ឆ្នាំ**១៩៧៥** និង **១៩៧៦** រដ្ឋកម្ពុជាប្រជាធិបតេយ្យ នៃពួកខ្មែរក្រហម បានបញ្ជូនទ័ព ទៅបណ្តេញទ័ពយួន(កុម្មុយនីស្ត) ពីកោះត្រល់និងកោះ ក្រចកសេះ ដើម្បីកាន់កាប់ជាថ្មីវិញ ។ បន្ទាប់ពីការវាយប្រហារគ្នា យ៉ាងឃោរឃៅបំផុត ពួកខ្មែរក្រហមត្រូវបរាជ័យ ប៉ុន្តែបរាជ័យនេះ មិនមានន័យថា កម្ពុជាត្រូវបាត់បង់សិទ្ធិដ៏ត្រឹមត្រូវរបស់ខ្លួន ក្នុងការការពារទឹកដីជាតិទេ[16] ។ នាពេលថ្មីៗនេះទៀត នៅក្នុងការប្រកាស់ជាលាយល័កអក្សរ ចុះថ្ងៃទី១៦ តុលា **២០០៥** សម្តេចនរោត្តម សីហនុ បានរំលឹកច្បាស់ថា លោក«*មិនបានយល់ស្របតាមបារាំង អំពីខ្សែបន្ទាត់ប្រេវិយេ ទេ... ពីព្រោះវាជាខ្សែខុសច្បាប់(អន្តរជាតិ) ហើយអយុត្តិធម្ម ចំពោះកម្ពុជា*» ហើយលោក«*មិនបានយល់ព្រម អំពីការបង្វិលកម្ពុជាក្រោម និងកោះត្រល់ ឲ្យទៅបារាំងនិងយៀកណាម ទេ...*»(ឯកសារ *A13) ។ អាស្រ័យហេតុការណ៍ទាំងអស់ខាងលើហ្នឹង តើហ៊ុន សែន បានធ្វើយ៉ាងម៉េច ដើម្បីបញ្ចេញបានផែនទីសមុទ្រខ្មែរ ដែលថា ”គេបានតម្កល់ នៅអង្គការសហប្រជាជាតិ នាឆ្នាំ១៩៦៤” នោះ ? ។

10- យើងឃើញថា ការអះអាងខាងលើ របស់ហ៊ុន សែន គ្រាន់តែជាឧបករណ៍ប្រឌិត សំរាប់បង្ហាញការសមហេតុផល នៃការកាត់កោះត្រល់ (និងក្រុមកោះក្រចកសេះ **ដែលគ្មានទាក់ទិននិង”ខ្សែប្រេវិយេ”សោះ**!) ឲ្យទៅយួន ដែលគាត់បានធ្វើ នាឆ្នាំ១៩៨២ ។ អញ្ចឹងហើយ ទើបគាត់បានពន្យល់យ៉ាងលឿនថា «*លោក ប្រេវិយេ បានដាក់កោះត្រល់ ឲ្យស្ថិតនៅក្រោមការ គ្រប់គ្រងរបស់**វៀតណាម***

[15] វរសេនីយឯក សាក់ ស៊ុត សាខន ។

[16] ឯកសាររបស់ (រដ្ឋមន្ត្រី ក្រសួងការពារជាតិ ខ្មែរក្រហម) សុន សេន ៖ The Son Sen Files, 1976-1977, NR34 Report to Brother 89, http://www.yale.edu/cgp/sonsenfiles.html


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

*(កូសាំងស៊ីន) ហើយនៅឆ្នាំ១៩៤៩ កូសាំងស៊ីនត្រូវបានបារាំង ប្រគល់ទៅឲព្រះចៅបាវដាយ»*...។ យើងត្រូវដឹងថា ទី១- កូសាំងស៊ីន *មិនមែន*ជាដែនដីរបស់វៀតណាមទេ តែជាដែនអាណានិគម **របស់**ប្រទេសបារាំង ។ ទី២- បារាំង រួមទាំងលោកប្រេវីយេផង មិនដែលបានគិតថា គេអាចដាក់កោះត្រល់ នៅក្រោមអធិបតេយ្យ នៃកូសាំងស៊ីន នោះទេ។ មូលហេតុមានច្រើន ៖ ជាបឋម គឺនាឆ្នាំ១៨៦៧ របាយការណ៍មួយ នៃទេសាភិបាលបារាំងនៃកូសាំងស៊ីន បានបញ្ជាក់ថាយួន មិនដែលបានកាន់កាប់កោះត្រល់ឡើយ ដោយសរសេរថា «*អភិបាលអាណ្ណាម នៃខែត្រហាទៀង មិនដែលទៅត្រួតពីនិត្យអ្វី នៅកោះភូកុក (កោះត្រល់)ទេ* »។ ៣៦ឆ្នាំបន្ទាប់មក របាយការណ៍ចុះថ្ងៃទី៣ មករា ១៩១៣ នៃ អភិបាលបារាំងនៃខែត្រហាទៀង ឈ្មោះ *ហ្វួរនីយេ* (Fournier) ទៅឲ្យទេសាភិបាលបារាំងនៃកូសាំងស៊ីន មានសេចក្ដីជាអាទិថា«*ទោះជាខ្ញុំបានស្រាវជ្រាវ យ៉ាងល្អិតល្អន់បំផុតហើយក្ដី ខ្ញុំពុំបានរកឃើញ នូវឯកសារជាផ្លូវការណាមួយ ជាបែបយ៉ាងណាក្ដី ដែលប្រាប់ថា តើកោះណាខ្លះស្ថិតនៅក្រោមអំណាចនៃខែត្រ(ហាទៀង)ទេ គឺថា យើងគ្មានឯកសារ ដែលប្រាប់ថាកោះណាខ្លះជារបស់កូសាំងស៊ីន ហើយកោះណាទៀត ជារបស់កម្ពុជាទេ*»[17]។ ប៉ុន្តែ ចាប់ពីឆ្នាំ១៩១៣នោះដែរ ពួកសហគ្រិនបារាំង បានចាប់អារម្មណ៍និងផលប្រយោជន៍ ដែលគេអាចទាញយកបាន អំពីកោះនានា នៅជិតឆ្នេរសមុទ្រខ្មែរ មានកោះត្រល់ ជាដើម។ អភិបាលបារាំងនៃខែត្រកំពត បានទទួលពាក្យស្នើជាច្រើន សុំសម្បទានរុករករ៉ែ នៅលើកោះនានា ដែលគេបានដឹងទៀតថា គេ«អាចចាប់បានត្រីច្រើនណាស់» ពីទឹកនៅជុំវិញនោះ។ ហេតុនេះ នាឆ្នាំ១៩១៣ និង១៩១៤ អ្នកទទួលខុសត្រូវបារាំង នៅខាងកូសាំងស៊ីន និងខាងកម្ពុជា បានសរសេរសំបុត្រតវ៉ាគ្នាជាច្រើន អំពីបញ្ហាកម្មសិទ្ធិ លើកោះទាំងនោះ ។ គេបានយករឿងហ្នឹង ទៅឲអគ្គទេសាភិបាលនៃឥណ្ឌូចិន ពីនិត្យពិចារណា ប៉ុន្តែ អគ្គទេសាភិបាល មិនបានធ្វើសេចក្ដីសំរេចអ្វីទេ ។ គេត្រូវរង់ចាំ២៥ឆ្នាំបន្ទាប់មកទៀត ទើបអគ្គទេសាភិបាល ឈ្មោះ **ហ្ស៊ុល ប្រេវីយេ** (Jules Brévié) - ដែលបានមកកាន់ការនៅឥណ្ឌូចិន តាំងពីខែកញ្ញា ១៩៣៦ - ហើយដែលពិតជាបានយល់ នូវស្ថានភាពយុទ្ធសាស្ត្រ នៃកោះត្រល់ ក្នុងពេលដែលជប៉ុន កំពុងធ្វើសង្គ្រាមរាតត្បាត ចូលកាន់កាប់ប្រទេសចិនហើយ(ខែធ្នូ ១៩៣៧) បានសំរេចចិត្តជាប្រញាប់ ចេញ«សារាចរ»អំពីខ្សែបន្ទាត់«ប្រេវីយេ» ដែលឲដាក់កោះខ្មែរមួយចំនួន រួមទាំងកោះត្រល់ នៅក្រោម«រដ្ឋបាល-កិច្ច» នៃកូសាំងស៊ីន របស់ប្រទេសបារាំង[18]។ យើងត្រូវដឹងទៀតថា នាឆ្នាំ១៩៣០ បារាំងបានបោះពុម្ភផែនទី នៃឥណ្ឌូចិន ដោយដាក់កោះត្រល់ ជារបស់កម្ពុជា (ឯកសារ *A14) ។

---

[17] ក្នុងសៀវភៅរបស់ សារិន ឆាក ៖SARIN CHHAK, *Les Frontières du Cambodge*, Tome I, 1966, p. 153

[18] ក្នុងអត្ថបទរបស់លោក ឌី ការ៉េត *៖ស្ថានភាពយុទ្ធសាស្ត្រ នៃកោះត្រល់ និងខ្សែបន្ទាត់ប្រេវីយេ* - ការផ្សាយនៃ គ.ព.ក. ទីក្រុងប៉ារីស ថ្ងៃទី៩ កញ្ញា ២០១២ ។


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

ទោះបីយ៉ាងនេះក្តី ប្រេវីយេ ក៏មិនបានសំរេចថា កូសាំងស៊ីនជា"អ្នកគ្រប់គ្រង" ក្នុងឋានៈជា**ម្ចាស់**នៃកោះត្រល់ និងកោះខ្មែរឯទៀតនោះទេ ។ ប្រេវីយេ បានសរសេរច្បាស់ នៅលើ«សារាចរ»របស់គាត់ ថា "ស្ថានភាពនៃចង្កោមកោះនេះ ដែលដុះរាយ នៅតាមបណ្តោយឆ្នេរសមុទ្រខ្មែរ ហើយដែលមានខ្លះឋិតនៅសែនជិត ឆ្នេរសមុទ្ររបស់ខ្មែរ ដែលដី(ល្បាប់) ដែលកំពុងដុះ និងចេះតែដុះបន្តទៅនឹងភ្ជាប់កោះទាំងនេះ ទៅនិងឆ្នេរសមុទ្រ របស់ប្រទេសកម្ពុជា ក្នុងរយៈកាលខ្លីខាងមុខ។ តាមការសមហេតុផល និងតាមស្ថានភាពភូមិសាស្រ្ត ការចាំបាច់តម្រូវ ឲ្យគេដាក់កោះទាំងនេះ ឲ្យនៅក្រោមរដ្ឋបាល នៃប្រទេសកម្ពុជា" (ឯកសារ *A15)។ ម៉្យាងទៀត សារាចរនេះ ជាការសំរេចផ្ទាល់ខ្លួន ("ខ្ញុំសំរេចថា...") នៃអគ្គទេសាភិបាលប្រេវីយេ ដោយពុំមានការយល់ព្រម ជាបឋម នៃអាជ្ញាធរកម្ពុជា គឺថាជាការរំលោភអំណាច នៃអគ្គទេសាភិបាល លើកិច្ចព្រមព្រៀងនានា នាទសវត្ស១៨៧០ រវាងប្រទេសបារាំង និងប្រទេសកម្ពុជា ។ ចំណែកឯហេតុសំអាង នៃការសំរេចចិត្តវិញ គាត់ថា "ដើម្បីសំរួលការធ្វើដំណើរ...នៃអ្នកដែលចង់ទាក់ទង និងរដ្ឋការកូសាំងស៊ីន" ដែលនេះជា បញ្ហាកំប៉ិកកំប៉ុកប៉ុណ្ណោះ ។ ក្នុងចំណុចចុងក្រោយ ដោយពីតជាចង់សូមទោស និងផ្តល់ការធានា ដល់ពួកខ្មែរ ដែលតវ៉ាយ៉ាងត្រឹមត្រូវនោះ លោកអគ្គទេសាភិបាល ដ៏មានមហិទ្ធិឫទ្ធិ មិនហ៊ានសំរេច អំពីអធិបតេយភាពទេ ដោយសរសេរថា៖ "**គេត្រូវចាំច្បាស់ថា នេះគ្រាន់តែជាបញ្ហារដ្ឋបាលកិច្ច និងកិច្ចការប៉ូលីសប៉ុណ្ណោះ។ រីឯបញ្ហា នៃការចំណុះនៃកោះទាំងនោះ ទៅប្រទេសណាវិញ ត្រូវនៅទុកបំរុង ទាំងស្រុង**"។

ការបូកបញ្ចូលគ្នា នូវជំនឿសមហេតុសមផលផង ជាមួយនិងហេតុសំអាងកំប៉ិកកំប៉ុកផង រួមទាំងការមិនដាច់ស្រេចចុងក្រោយផងនេះ ជាការបង្ហាញច្បាស់ នូវភាពបណ្តោះអាសន្ន នៃសេចក្តីសំរេចចិត្ត របស់ប្រេវីយេនោះ ។ សភាពការណ៍នេះ បានលេចមកច្បាស់ទៀត នៅលើគំនូសផែនទីនៃ"ខ្សែប្រេវីយេ" ដែលជាការបង្កើតថ្មីមួយចម្លែក ដោយខ្សែនេះ មិនមែនជាបន្ទាត់ត្រង់រហូតទេ តែវាមានរាងដូចកណ្តៀវ ដែលមានដងត្រង់ ផ្តើមចេញមកពីចំណុចដីគោក ហើយបែរទៅកងកៀរយកកោះត្រល់ទាំងមូល ។ ចំពោះសេចក្តីសំរេចបែបនេះ គឺគ្មា អ្នកនិតិសាស្រ្ត ម៉ត់ចត់ណាម្នាក់ យល់ថាវាមានតម្លៃត្រឹមត្រូវទេ។

**១១**- ការប្រាកដទី១ គឺ **"ខ្សែប្រេវីយេ"នៃឆ្នាំ១៩៣៩ មិនមែនជាខ្សែព្រំដែនអន្តរជាតិ រវាងកូសាំងស៊ីន (គឺ ប្រទេសបារាំង) និងកម្ពុជា** ឬជា *"ខ្សែព្រំដែនមិនកែប្រែ"* តាមគោលការណ៍ *«អ៊ុទី ប៉ូស៊ីដេទីស» (*Uti possidetis*)* ដូចដែលហ៊ុន សែន បាននិយាយបន្លំបំភាន់នោះឡើយ ។ ទី២ គឺ **"ខ្សែប្រេវីយេ" ឆ្នាំ១៩៣៩ ត្រូវចប់នៅត្រឹមកោះត្រល់** ដោយគេមិនបានបន្តវា ចុះទៅក្រោមទៀត ហើយបញ្ចូលក្រុមកោះក្រចកសេះ ឬ កោះអ្វីទៀត.. ទៅក្រោមរដ្ឋបាលកិច្ច នៃកូសាំងស៊ីនទេ ។ នាឆ្នាំ១៩៤៩ ប្រទេសបារាំងបានសំរេច ធ្វើការរំលាយអាណានិគមរបស់ខ្លួន (la Décolonisation) នៅឥណ្ឌូចិន គឺថាជា


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

ការរំលាយលក្ខន្តិកៈ នៃដែនកូសាំងស៊ីន ដែលគេបានបង្កបង្កើត ពីឆ្នាំ១៨៥៩មក ។ តាមការធម្មតា នៃការប្រព្រឹត្តក្នុងពិភពលោក ទឹកដីដែលគេបានចាប់ផ្ដុំគ្នា ជាដែនអាណានិគមនោះ គេត្រូវតែបង្វិល ទៅឲម្ចាស់ដើមផ្សេងៗរៀងខ្លួនវិញ[19]។ ប៉ុន្តែ បារាំងបានរំលោភលើសិទ្ធិកម្ពុជាទៀត ដោយបង្វិលដែន កូសាំងស៊ីនទាំងមូល ឲ្យទៅអាណ្ណាម នៃស្ដេចអធិរាជ*បាវដាយ* ដែលជាបុព្វហេតុនៃការតវ៉ាជាខ្លាំង ដ៏ត្រឹមត្រូវ របស់ខ្មែរ តាំងពីឆ្នាំ១៩៤៩ រហូតដល់ក្នុងសន្និសិទនៃទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ និងមក ទល់បច្ចុប្បន្នកាលនេះ ។ ក្នុងករណីពីសេស នៃ"សារាចរ"និង"ខ្សែប្រេវីយេ" ដែល"*គ្រាន់តែជាបញ្ហា* **រដ្ឋបាលកិច្ច**" វាត្រូវរលាយរលត់ជាស្វ័យប្រវត្តិ ជាមួយនិងការរំលាយ អាណានិគមនោះហើយ ។ ហេតុនេះ"*ចង្កោមកោះនេះ ដែលដុះរាយនៅតាមបណ្ដោយឆ្នេរសមុទ្រខ្មែរ* "រួមទាំងកោះត្រល់ ដែល គេបានកត់ក្នុង"សារាចរប្រេវីយេ" ហើយដែលគ្មានចំណងភូមិសាស្ត្រ ឬនយោបាយអ្វី ជាមួយ និង អតិតកូសាំងស៊ីននោះ វាត្រូវតែវិលមកនៅក្រោមចំណុះនៃកម្ពុជាវិញ ជាស្វ័យប្រវត្តិ ដោយសារការ រលាយរលត់ នៃ"សារាចរ"និង"ខ្សែប្រេវីយេ"ហ្នឹង ។ ពួកយួនបានយល់ អំពីស្ថានភាពប្រវត្តិសាស្ត្រ នេះហើយ ទើបគេមិនដែលចាត់ទុកថា "ខ្សែប្រេវីយេ"ជាខ្សែព្រំដែនសមុទ្រ ជាមួយនិងកម្ពុជាទេ ។ ចំណុចធំ គឺយួនពុំមានការសំអាងលើច្បាប់ ឬលើព្រឹត្តការណ៍ជាប្រវត្តិសាស្ត្រអ្វីសោះ ក្រៅពីកម្លាំង កាំភ្លើង-កាណុងរបស់ខ្លួន ដើម្បីកាន់កាប់កោះត្រល់ កោះក្រចកសេះ កោះវ៉ៃ... របស់កម្ពុជា ។ យួន បានបញ្ចេញជំហច្បាប់ព្រៃហ្នឹង ជាថ្មីទៀត នៅក្នុង"កិច្ចព្រមព្រៀង ស្ដីពីតំបន់ទឹកប្រវត្តិសាស្ត្រ" ជា មួយ ហ៊ុន សែន ចុះថ្ងៃទី៧ កក្កដា ១៩៨២ ដើម្បីកាត់យកកោះខ្មែរទាំងនោះ និងតំបន់សមុទ្រខ្មែរ មួយភាគធំថែមទៀត បញ្ចូលទៅយៀកណាម ដោយគ្មានការពន្យល់ហេតុផលអ្វីមួយម៉ាត់ ។

12- ក្នុងរឿងកោះវ៉ៃ (ពូឡូ វ៉ៃ) ហ៊ុន សែន (នាថ្ងៃទី១ សីហា ២០១២) បានដេរប្រមាថយ៉ាង ក្លាហានបំផុត ថា"*ពួកអាសាធារណៈរដ្ឋ លន់ នល់ វាកំសាកណាស់... ពួកហ្វែងមិនហ៊ានទៅរំដោះ កោះវ៉ៃ ដែលពួក(យួនខាងត្បូង)ជីវ-គី បានកាន់កាប់ទេ... គឺអញទេ ហ៊ុន សែន ដែលបានយកកោះ វ៉ៃ មកឲ្យកម្ពុជាវិញ នៅឆ្នាំ១៩៨២ !...*"។ លុះគាត់ធ្វើរបាយការណ៍ នាថ្ងៃទី៩ សីហា បន្ទាប់មក ហ៊ុន សែន បានអះអាងបញ្ជាក់ ទៀត ថា"*នៅឆ្នាំ១៩៧៤ កម្លាំងពួកជីវ-គី នៃយៀកណាមខាងត្បូង បានប្រកាសកាន់កាប់កោះវ៉ៃនេះ ដោយបានដាក់ទ័ពនៅលើកោះ និងបានបញ្ជាកុប៉ាល់រកប្រេង របស់ ក្រុមហ៊ុនបារាំង ELF(-ERAP) ឲ្យចាកចេញ ក្នុងរយៈពេល១៥ថ្ងៃ ។ ក្រុមហ៊ុនបារាំងនេះ ក៏បាន បញ្ឈប់ការរុករកប្រេង ហើយចាកចេញ ពីតំបន់កោះនេះទៅ*" ។ ការអួតអាងទាំងនេះ ជាការភរភូត

---

[19] តាំងពីឆ្នាំ១៨៥៦ ព្រះបាទអង្គឌួង បានធ្វើលិខិតជាផ្លូវការ ទៅព្រះចៅអធិរាជបារាំង ណាប៉ូឡេអុង ទី៣ រៀបរាប់ប្រាប់ សព្វគ្រប់ នូវសិទ្ធិរបស់កម្ពុជា ជាម្ចាស់ដើមនៃទឹកដី នៅកម្ពុជាក្រោម ។ ថ្មីៗនេះ ព្រះបាទ នរោត្តម សីហនុ ក៏បានបញ្ជាក់ ទៀតដែរ ថា« យ៉ាងហោចណាស់ ទំហំទឹកដីពាក់កណ្ដាល នៃកូសាំងស៊ីននោះ ជារបស់កម្ពុជា » ។


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

ទាំងស្រុងទៀត ។ ហ៊ុន សែន គួរដឹងថា ទី១- កោះវ៉ៃ នៅ ក្រោមការត្រួតត្រាជានិច្ចកាល នៃកម្ពុជា តាំងពីឆ្នាំ**១៩៥៣** ដល់ខែ**មេសា ១៩៧៥** ។ ទី២- នា**ថ្ងៃទី៦ កុម្ភៈ ១៩៧០** រដ្ឋាភិបាលកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណ ដល់ក្រុមហ៊ុនបារាំង ឈ្មោះអែលហ្វ៍-អេរ៉ាប (ELF-ERAP) ដើម្បីធ្វើការស្រាវជ្រាវ ក្នុងខ្ពង់រាបនៃដែនសមុទ្រ *ទាំងមូល* នៃប្រទេសខ្មែរ ។ ក្រុមហ៊ុននេះ បានធ្វើសំណង់ ជាច្រើននៅលើកោះវ៉ៃ សំរាប់ការងាររបស់គេ មានជាអាទិ ការបោះបង្គោលបញ្ជាក់ក្រឡាផ្ទៃដី និងបញ្ជាក់ភូមិសាស្ត្រ ថាកោះវ៉ៃ ជាកម្មសិទ្ធិរបស់កម្ពុជា និងទីលានមួយ សំរាប់ឧទ្ធម្ភាគចក្រធុនធ្ងន់"ស៊ីគ័កស្គី" (Sikorsky) ដើម្បីការដឹកនាំពួកអ្នកបច្ចេកទេស ពីប្រទេសម៉ាឡេ មកធ្វើការងាររាល់ថ្ងៃ។ ការជីកអណ្តូងរកប្រេងទី១ ឈ្មោះH1 បានផ្តើមនាខែកញ្ញា ១៩៧២ នៅ៥០គ.ម. ខាងត្បូងកោះវ៉ៃ ។ ការរុករកប្រេង នៅតំបន់កោះវ៉ៃ បានផ្តើមធ្វើនា ខែកញ្ញា ១៩៧២ ។ រដ្ឋមន្ត្រី និងគណៈប្រតិភូនៃរដ្ឋាភិបាលខ្មែរ បានទៅពិនិត្យការងារផ្សេងៗ នាចុងខែធ្នូ ១៩៧២ ។ ការថែរក្សាសំណង់និងឧបករណ៍ទាំងអស់នេះ ត្រូវបានបញ្ចប់ នាខែមិថុនា ១៩៧៤ ដោយគេត្រូវបញ្ឈប់ការរុករក នៅអណ្តូងទី២ ឈ្មោះL1 ដែលនៅខាងមុខកោះក្រចកសេះ (ពូឡូ ប៉ងយ៉ង) និងអណ្តូងទី៣ ឈ្មោះB1 នៅមុខកោះតាង ដែលគេពុំបានរកឃើញផលអ្វីសំខាន់ ។ ការពិត កុប៉ាល់យាមល្បាតយួនខាងត្បូងមួយគ្រឿង បានបើកមកជិតអណ្តូងរកប្រេងទី២ មួយដងគត់ នៅមុខ***កោះក្រចកសេះ*** (ពូឡូ ប៉ង់យ៉ង) - មិនមែននៅ*កោះវ៉ៃ* ដូចហ៊ុន សែន អះអាងទេ - នាខែសីហា ១៩៧៤ ហើយបានប្រាប់ឲ្យក្រុមហ៊ុនអែលហ្វ៍ បញ្ឈប់ការងាររបស់គេ រួចហើយក៏ត្រឡប់ទៅវិញ ដោយគ្មានបានដាក់ទំពអ្វីប្រចាំការទេ ។ ដោយបានដឹងរឿងនេះ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បានធ្វើកំណត់ការទូត ជំទាស់និងការ ចូលជ្រៀតជ្រែកនោះ ទៅឲ្យរដ្ឋាភិបាលយៀកណាមខាងត្បូង ហើយបញ្ហាហ្នឹងក៏បានស្ងប់ស្ងាត់ទៅ ។ លោក ហ្សេអង់-ក្លូដ ឡូត (Jehan-Claude LOT) ដែលជាអតិតនាយក នៃក្រុមហ៊ុនអែលហ្វ-អេរ៉ាប ប្រចាំកម្ពុជា បានសរសេរបញ្ជាក់ថា *"យៀកណាមខាងត្បូង នាសម័យនោះ* (ពីខែកុម្ភៈ **១៩៧០** ដល់ខែមិថុនា **១៩៧៤**) *មិនដែលបានជំទាស់អ្វី និងកិច្ចការ(របស់ក្រុមហ៊ុន)យើង ដែលធ្វើនៅក្រោមអធិបតេយភាពខ្មែរ លើកោះវ៉ៃ ទេ"* (ឯកសារ *A16) ។ ជាបន្ទាប់មក គឺនៅក្នុងរបប ប៉ុល ពត កងទ័ពយួនកុម្មុយនីស្ត៍ ដែលផ្តើមច្បាំងនិងទ័ពខ្មែរក្រហម បានចូលកាន់កាប់កោះវ៉ៃ នាថ្ងៃទី១០ មិថុនា ១៩៧០ ហើយបានដកខ្លួនចេញវិញ នាថ្ងៃទី ១២ សីហា ១៩៧០[20] ។ ហេតុនេះ ក្នុងការដាក់ស្តែងប្រវត្តិសាស្ត្រ កោះវ៉ៃ មិនដែលត្រូវបានយួនណាមួយ ត្រួតត្រាទេ ហើយហ៊ុន សែន ក៏គ្មានបានទៅយកផេះអ្វីមួយក្តាប់ ពីយួនឡើយ ។

[20] ក្នុងអត្ថបទ របស់សារព័ត៌មានបារាំង ឡឺម៉ុង ៖ journal français LE MONDE n°9456 du 14 juin 1975, et n° 9504 du 12 août 1975



c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

# ការបោះបង់ កោះត្រល់ និង ចង្កោមកោះក្រចកសេះ ឲ្យទៅយួន
# និង *"កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ"*

**១៣**- ប៉ុន្តែ ជាលើកទី១ នៅក្នុងប្រវត្តិសាស្ត្រខ្មែរ គឺហ៊ុន សែន ដែលបានកាត់បោះបង់ កោះត្រល់ និង ចង្កោមកោះក្រចកសេះ របស់ខ្មែរ ឲ្យទៅយួន តាមរយៈ*"កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ"* នៃថ្ងៃទី៧ កក្កដា ១៩៨២ ។ ហេតុនេះ នៅគ្រប់កន្លែង នៃរបាយការណ៍ដ៏វែងអន្លាយរបស់គាត់ ហ៊ុន សែន បានខឹតខំបង្ហាញ"ភស្តុតាង" ដែល**តម្រូវ**ឲ្យគាត់ស៊ីញេ "កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ" ជាមួយយួន និងកាត់កោះត្រល់ និងចង្កោមកោះក្រចកសេះ ឲ្យទៅយួន។ យើងបានដឹងហើយថា នៅទសវត្ស១៩៨០ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ហ៊ុន សែន និងក្រុមគាត់ បានសារភាពថា ខ្លួនគ្មានឯកសារច្បាស់លាស់ ជាបង្គោលទេ ។ ប៉ុន្តែ នៅថ្ងៃនេះ ហ៊ុន សែន ស្រាប់តែរកបាន"សំបុត្រ"របស់ព្រះករុណា នរោត្តម សីហនុ ចុះ**ថ្ងៃទី២៧ កញ្ញា ១៩៩៩** ផ្ញើទៅឲ្យ ផាម យ៉ាំង ដុង (អតិតរដ្ឋមន្ត្រីទី១ យួនកុម្មុយនីស្ត៍) ដែលមាន*សេចក្តីស្នើ* ស្របទាំងស្រុង និងយោបល់របស់ហ៊ុន សែន (ពីឆ្នាំ**១៩៨២**) ក្នុងបញ្ហានៃ"ខ្សែបន្ទាត់ប្រេវីយេ" និងការបោះបង់កោះត្រល់ និងចង្កោមកោះក្រចកសេះ ឲ្យទៅយួន ដោយថា*"កម្ពុជា(នៃសម្តេច សីហនុ)បានទាមទារជានិច្ច ឲ្យយកខ្សែប្រេវីយេ ជាព្រំដែនសមុទ្រ"*... គឺថាវាផ្ទុយទាំងស្រុង និងសេចក្តីសំរេចជាផ្លូវការ ជាបន្តបន្ទាប់ តាំងពីទសវត្ស១៩៥០មក នៃសម្តេចសីហនុ និងរាជរដ្ឋាភិបាលនានារបស់លោក ។ សំបុត្រហ្នឹង ហ៊ុន សែន បានឲ្យគេផ្សាយជាលើកដំបូង នាថ្ងៃទី១៨ តុលា ២០០៥ បន្ទាប់ពីគាត់បានជេរប្រមាថ ដល់អតិតព្រះមហាក្សត្រនានា ថា"បានកាត់ទឹកដីខ្មែរ ឲ្យទៅបរទេសជិតខាង"[21] ។ តែពេលនោះ ក៏ជាពេលដែលហ៊ុន សែន កំពុងតែស្រែកយ៉ាងសន្ធាប់ បង្ខំឲ្យរដ្ឋសភា និងព្រះមហាក្សត្រនរោត្តម សីហមុនី ផ្តល់សច្ចាប័នដល់"កិច្ចព្រមព្រៀងបន្ថែម" លើកិច្ចព្រមព្រៀងអំពីទឹកដី ដែលគាត់បានស៊ីញេ ជាមួយយួន ។ ហេតុនេះ គ្មាននរណាបានចាប់អារម្មណ៍ និង"សំបុត្រនៃសម្តេចសីហនុ"នេះទេ ដោយគេយល់ថា វាជាការប្រឌឹតរបស់ហ៊ុន សែន ដើម្បីតម្លើងកំដៅខ្លាំងថែមទៀត ដល់បរិយាកាសនយោបាយតឹងតែង នាពេលនោះ ហើយជាពិសេស សម្តេច សីហនុ ទើបតែបានផ្សាយជាថ្មីទៀត (ថ្ងៃទី១៦ តុលា ២០០៥) នូវការបញ្ជាក់ថា លោកមិនបានយល់ស្របតាមបារាំង អំពីខ្សែបន្ទាត់ប្រេវិយេទេ (ឯកសារ * A13)។ ជាបន្ទាប់មក នាថ្ងៃទី៥ វិច្ឆិកា ២០០៥ សម្តេចសីហនុ ក៏បានធ្វើការកែតម្រូវ នៅក្នុងរឿងហ្នឹងទៀត (ឯកសារ *A17)...។ ទោះជាយ៉ាងណាក្តី នៅក្នុងនិតិរដ្ឋ

[21] ក្នុងអត្ថបទ សារព័ត៌មាន ៖ KONG SOTHANARITH, *Frontières - Le prince Thomico Sisowath a quitté le pays*, Cambodge Soir, Phnom-Penh, 19-10-2005


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

សេចក្តីស្នើផ្ទាល់ខ្លួន ឬការពិភាក្សាការងារ ជាសាធារណៈក្តី ជាសម្ងាត់ក្តី នៃអ្នកតំណាងរដ្ឋ ទោះជាប្រមុខរដ្ឋក្តី មិនមានសុពលភាពច្បាប់ទេ ដរាបណាវាមិនបានចេញផល ជាកិច្ចផ្លូវការជាសាធារណៈ ។ ប៉ុន្តែហ៊ុន សែន បានទាញសេចក្តីសារុបមកថា"*យោងលើភាពចាំបាច់នេះ រដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាមានិតកម្ពុជាកាលនោះ (គឺ ហ៊ុន សែន) ក៏បានចរចា ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋ សង្គមនិយមវៀតណាម ហើយស្រុះស្រួលគ្នា រៀបចំជាកិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ ឆ្នាំ១៩៨២ ដោយបានកំណត់យក តំបន់ទឹកប្រវត្តិសាស្ត្រនេះ ម្ខាងពីចំណុចកោះវ៉ៃ ដែលជាកោះរបស់កម្ពុជា ហើយតភ្ជាប់ ទៅនិងចំណុចម្ខាងទៀត គឺកោះថូជូ (កោះក្រចកសេះ) ដែលជាកោះរបស់វៀតណាម*"[22]។

ជាមួយនិងការប្រើព្រះនាមនរោត្តម សីហនុ ជា"ប្លាកគ្របមុខ"នេះ ហ៊ុន សែន ដូចជាបានទ្រង់ញាណដឹង តាំងពីឆ្នាំ១៩៨២ម្លេះ ថា នៅឆ្នាំ១៩៩៩ សម្តេចសីហនុ នឹងសរសេរ"សំបុត្រ"បែបហ្នឹង ទៅឲ្យផាម យ៉ាំង ដុង ទើបខ្លួនគាត់និងយួន (ង្វៀង កូ ថាច់) បានសំរេចចិត្តចុះ"កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ" នាថ្ងៃទី ៧ កក្កដា ១៩៨២ ជាមុនស្រេចទៅ ! ។ តែ ការណ៍មួយយ៉ាងចម្លែក គឺនៅក្នុងការផ្សាយនៃ"អត្ថបទគោល" របស់ហ៊ុន សែន (ចុះថ្ងៃទី៩ សីហា ២០១២) គាត់មិនបង្ហាញអត្ថបទនៃ "កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ"នេះ នៅក្នុងឧបសម្ព័ន្ធ ជាសាធារណៈទេ ដោយបង្ហាញតែគំនូសផែនទី ដែលគេបានភ្ជាប់ ជាមួយនិងកិច្ចព្រមព្រៀងនោះ ប៉ុណ្ណោះ ។ ដូចគ្នានេះដែរ គេមិនបង្ហាញអត្ថបទ នៃ"ក្រឹត្យ"របស់ ហេង សំរិន ចុះថ្ងៃទី៣១ កក្កដា ១៩៨២ ស្តីអំពីការកំណត់ ខ្សែបន្ទាត់មូលដ្ឋាន នៃដែនសមុទ្រ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីអនុវត្ត"កិច្ចព្រមព្រៀង ស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ"នោះ។ តើ វាមាន"ការសម្ងាត់"អ្វីនៅក្នុងនោះ ដែលហ៊ុន សែន នៅតែមិនចង់ឲប្រជាជនខ្មែរដឹង (ប៉ុន្តែពិភពលោកបាន ដឹងអស់ហើយ) ? ។ "ការសម្ងាត់"ទាំងនោះ គឺសេចក្តីសំអាងសំខាន់ៗ នៃកិច្ចព្រមព្រៀងហ្នឹង (ឯកសារ *A18) ជាបឋមបំផុត គឺ ហ៊ុន សែននិងយួន "*មានបំណង* ***ពង្រឹងនិងពង្រីកថែមទៀត នូវទំនាក់ទំនងពិសេស កម្ពុជា-វៀតណាម*** *ក្នុងស្មារតីនៃសន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះហត្ថលេខា នាថ្ងៃទី១៨ កុម្ភៈ ១៩៧៩*"... ហើយនៅក្នុង"បំណង"នេះ គេ"*យល់ឃើញ****សភាពជាក់ស្តែង*** *ថា... កោះហ្វូកុក (គឺកោះត្រល់) និងប្រជុំកោះថូជូ (គឺកោះក្រចកសេះ) (ជា)របស់សាធារណរដ្ឋសង្គមនិយមវៀតណាម*" ជាស្រេចហើយ (!) ។ សេចក្តីសំអាងធំពីរទៀត នៃការបង្កើត"តំបន់ទឹកប្រវត្តិសាស្ត្រ" គឺ"***លក្ខណភូមិសាស្ត្រពិសេស និង សារៈ-សំខាន់យ៉ាងខ្ពស់ ក្នុងកិច្ចការពារជាតិ និងសេដ្ឋកិច្ច នៃប្រទេសទាំងពីរ***"

[22] ក្នុង"អត្ថបទគោល"របស់ហ៊ុន សែន ស្តីពីការងារព្រំដែនកម្ពុជា-យៀកណាម ចុះថ្ងៃទី៩ សីហា ២០១២ នៅទំព័រទី ២៤ និង ២៥។


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

។ គេគ្មានបានបន្លឺមួយម៉ាត់ នូវសេចក្តី សំអាងប្រវត្តិសាស្ត្រ ឬសេចក្តីសំអាងច្បាប់ជាតិ/អន្តរជាតិ ឬគោលការណ៍«*អ៊ុទី ប៉ូស៊ីដេទីស*» (Uti possidetis) ឬផលនៃ"បន្ទាត់ប្រេវីយេ" ឬវត្តមាននៃផែនទីសមុទ្រ កម្ពុជាឆ្នាំ១៩៦៤ ដូចដែលហ៊ុន សែន យកមកនិយាយបញ្ចូលរ៉ូងរ៉ាំង ឥឡូវនេះទេ ។ ផ្ទុយទៅវិញ សេចក្តីសំអាងរបស់គេទាំងនោះ វាមានន័យតែមួយ គឺយួនចក្រពត្រ ដោយឈរលើ"*សភាពជាក់ស្តែង*" បានសំរេចកាត់យកកោះ និងដែនសមុទ្រខ្មែរ ជាមួយនិងការសាទរនៃ ហ៊ុន សែន ត្បិតយួនបានក្លាយ ជាអ្នក**ការពារ**អាជ្ញាធរខ្មែរមួយ ដែលបានភ្ជាប់ខ្លួន"*ជាពិសេស*"ជាមួយគេពីថ្ងៃ ទី១៨ កុម្ភៈ ១៩៧៩ មកហើយ ។

**១៤-** ហ៊ុន សែន ក៏បានខំលាក់និងប្រជាជនខ្មែរដែរ អំពីការរំលោភអំណាច ដ៏ខ្លាំងក្លាមួយទៀតរបស់យួន ក្នុង"កិច្ចព្រមព្រៀង"ហ្នឹង គឺគេបានសំរេចយកផ្ទៃសមុទ្រខ្មែរ នៅខាងមុខកោះត្រល់ មានទំហំប្រមាណ ១០០០០គ.ម.ក្រឡា ធ្វើជា"តំបន់ទឹកប្រវត្តិសាស្ត្រ" ដែលថាត្រូវនៅ"*ក្រោមរបបច្បាប់ផ្ទៃក្នុង នៃប្រទេសទាំងពីរ*" ដោយសំអាងលើ"*ល័ក្ខខ័ណភូមិសាស្ត្រពិសេស និងសារៈសំខាន់នៃកិច្ចការពារជាតិ... នៃប្រទេសទាំងពីរ*"។ តើ"ល័ក្ខខ័ណភូមិសាស្ត្រ**ពិសេស**"នោះ វាយ៉ាងម៉េច ដែលគ្មាននរណាម្នាក់(ខ្មែរ និងបារាំងអាណានិគម) ធ្លាប់បានដឹងសោះ នៅក្នុងអតីតកាល? តើ"សារៈសំខាន់នៃកិច្ចការពារជាតិ"រួមគ្នាយួននិងខ្មែរ វាកើតមកជាប្រវត្តិសាស្ត្រ និងជាអចិន្ត្រៃយ៍ ពីកាលណាមក ដើម្បីឲ្យគេបញ្ចូលទឹកដីជាតិ ជាមួយគ្នាយ៉ាងនេះ?។ រឿងទាំងនេះ វាមានប្រភពកំណើតតែមួយដដែល គឺ"*សន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ*" ដែលគេបានធ្វើនាថ្ងៃទី១៨ កុម្ភៈ ១៩៧៩[23] ដែលយួនបានប្រើជាគ្រឹះមូលដ្ឋាន នៃ"សហព័ន្ធឥណ្ឌូចិន"របស់យួន ហើយដែលមកទល់ថ្ងៃនេះ ហ៊ុន សែន នៅតែមិនព្រមលុបបំបាត់ឡើយ ។ ប៉ុន្តែ ការបង្កើតហ្នឹង វាបានបណ្តាល នូវភាពស្មុកស្មាញ ដល់បញ្ហាអធិបតេយ្យ ក្នុងកិច្ចការពារ និងការទាញយកផលប្រយោជន៍ នៃដែនសមុទ្រកម្ពុជា ។ គេបានបន្ថែមទៀតថា ការកំណត់ខ័ណ្ឌសីមា នៃព្រំប្រទល់សមុទ្រ រវាងប្រទេសទាំងពីរក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ មិនទាន់ធ្វើទេ ហើយការយាមល្បាត និងការត្រួតពិនិត្យតំបន់នេះ ត្រូវធ្វើរួមគ្នា... (គឺ"រួមគ្នា" នៅក្រោមបញ្ជាការយួន)។ រីឯប្រជាជនក្នុងតំបន់ គេថាគាត់អាច"បន្តប្រកបរបរនេសាទ និងការយកផលផលសមុទ្រផ្សេងទៀត តាមទម្លាប់ដែលមានមកដល់ឥឡូវ"... ប៉ុន្តែ ពីពេលនោះមក ប្រជាជនខ្មែរត្រូវគេបណ្តេញ ពីតំបន់នោះជានិច្ច ដើម្បីកុំឲប៉ះពាល់ ដល់បញ្ហា"សន្តិសុខ"របស់គេ ហើយមានតែទាហ៊ានយួនប៉ុណ្ណោះ ដែលអាចចូលមកតាមចិត្ត ចាប់ត្រីក្នុងតំបន់ និងរហូតមកដល់មុខឆ្នេរសមុទ្រ នៃកម្ពុជាតែម្តង ។

[23] យៀកណាម និងឡាវកុម្មុយនីស្ត៍ បានធ្វើ*សន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ...* មានលំនាំដូចគ្នានេះចុះថ្ងៃទី ១៨ កក្កដា ១៩៧៧ ។


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

**១៥-** នៅក្នុង“កិច្ចព្រមព្រៀង”នេះ បន្ទាប់ពីគេបានកាត់យកកោះត្រល់ និងប្រជុំកោះក្រចកសេះ ដោយអំណាច ហើយយៀកណាម នៅតែមិនទាន់កំណត់ ខ្សែព្រំដែនសមុទ្ររបស់គេ ជាមួយខ្មែរ ។ គេគ្រាន់តែ*“ចាត់ទុកខ្សែ ហៅ"ប្រេវីយេ" គូសក្នុងឆ្នាំ១៩៣៩ ជា**ខ្សែបែងចែកកោះ** ក្នុងតំបន់នេះ”* ប៉ុណ្ណោះ ។ នេះមានន័យថា ដែនសមុទ្ររបស់យៀកណាម អាចនឹងរីកថែមទៀត មកខាងលិច ។ ប៉ុន្តែ នាថ្ងៃទី៣១ កក្កដា ១៩៨២ "ប្រមុខរដ្ឋ” ហេង សំរិន បានចេញក្រឹត្យ *“ស្ដីពីការកំណត់ តំបន់សមុទ្រ**ទាំងអស់** និងខ្ពង់រាបបាតសមុទ្រ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា* (ស.ប.ក.)” ហើយ សាធារណរដ្ឋនេះ "*មានអធិបតេយ្យភាព ពេញលេញ និងទាំងស្រុង*” លើដែនសមុទ្ររបស់ខ្លួន គឺថា ទាំងលើតំបន់ទឹកប្រវត្តិសាស្ត្រ ដែលជាសមុទ្រផ្ទៃក្នុងនៃកម្ពុជាដែរ ព្រមទាំងលើដែនអាកាសខាងលើផង (ឯកសារ *A19) ។ ការពិត វាខុសឆ្ងាយបន្តិច អំពីការអះអាងនេះ ។ នាថ្ងៃទី៣០ វិច្ឆិកា ១៩៨២នោះ ក្រុងហាណូយបានដាក់សេចក្ដីប្រកាស់ នៅអង្គការសហ-ប្រជាជាតិ អំពីបន្ទាត់មូលដ្ឋានថ្មី នៃដែនសមុទ្រយៀកណាម ហើយនាថ្ងៃទី១១ មិថុនា ១៩៨៤ គេបានដាក់ បន្ថែមទៀត នូវសេចក្ដីប្រកាស់ អំពីដែនអាកាសថ្មី របស់គេ ។ លោកសឺន សាន ជារដ្ឋមន្ត្រីទី១ នៃរដ្ឋ(ស្រប ច្បាប់)កម្ពុជាប្រជាធិបតេយ្យ បានប្រកាស់ នាថ្ងៃទី១២ មិនា ១៩៨៦ ថ្កោលទោស និងមិនទទួលស្គាល់ជាដាច់ខាត នូវកិច្ចព្រមព្រៀង”ទឹកប្រវត្តិសាស្ត្រ”នេះ ។ ជាបន្ទាប់មក សាធារណរដ្ឋសឹងហ្កាពួរ បានធ្វើកំណត់ ជាផ្លូវការ ចុះថ្ងៃទី៥ ធ្នូ ១៩៨៦ ទៅឲ្យលោកអគ្គលេខា នៃអង្គការសហប្រជាជាតិ ដើម្បីបរិហា"*របស់ហៅថា កិច្ចព្រមព្រៀងអំពីទឹកប្រវត្តិសាស្ត្រ រវាងសាធារណរដ្ឋសង្គមនិយមយៀកណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា*” ជាមួយគ្នានិងសេចក្ដីប្រកាស់ អំពីដែនសមុទ្រថ្មី និងដែនអាកាសថ្មី របស់យៀកណាម "*ដែលមិនស្របតាមវិធាន ដែលមានចែងច្បាស់ ក្នុងច្បាប់អន្តរជាតិ អំពីបញ្ហានេះ ដូចមានការកំណត់ នៅក្នុងមាត្រា៤ នៃអនុសញ្ញានៃទីក្រុងហ្សឺណែវ (ឆ្នាំ១៩៥៨) ស្ដីអំពីសមុទ្រដែនដី និងនៅក្នុងមាត្រា៧ នៃអនុសញ្ញានៃសហប្រជាជាតិ ឆ្នាំ១៩៨២ ស្ដីអំពីច្បាប់សមុទ្រ ដែលយៀកណាមជាហត្ថលេខី ដែរ* ” (ឯកសារ *A20) ។ គេមិនបានឃើញថា ក្រុងហាណូយបានឆ្លើយតប និងការចោទប្រកាន់ដ៏ធ្ងន់ធ្ងរ ទាំងនេះទេ ។ ផ្ទុយទៅវិញ នាថ្ងៃ ទី៧ សីហា ១៩៩៧ ក្រុងហាណូយបានយក កិច្ចព្រមព្រៀងអំពីទឹកប្រវត្តិសាស្ត្រហ្នឹង ធ្វើជាមូលដ្ឋាននៃកិច្ចព្រមព្រៀងមួយ រំលងលើក្បាលខ្មែរ(ហ៊ុន សែន) ដើម្បីកំណត់ដែនសមុទ្រ រវាងយៀកណាម និងថៃឡង់ ដោយឲ្យថៃឡង់បានពង្រីកដែនសមុទ្រខ្លួន ទំហំប្រមាណ ៣០០០០គ.ម.ក្រឡា មកលើកម្ពុជាថែមទៀត ។ អំណាចច្បាប់ព្រៃ វាចេះតែបន្តទៅមុខជានិច្ច ។

* *

*


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

# សេចក្តីបញ្ចប់

យើងបានដឹងហើយថា យួនមិនដែលគោរព កិច្ចព្រមព្រៀងអន្តរជាតិណាមួយទេ ទោះជាកិច្ចព្រមព្រៀងនោះ បានផ្តល់ប្រយោជន៍ច្រើន ដល់គេហើយក្តី ។ យៀកណាមសង្គមនិយមបច្ចុប្បន្ននេះ មានចរិតមិនខុសពី យៀកណាមចក្រពត្រនិយម-វាតទីនិយម នៃសតវត្សមុនៗទេ នៅចំពោះមុខរដ្ឋទន់ខ្សោយជិតខាង ដូចជា ប្រទេសចាម្ប៉ា ប្រទេសតូចៗនៃប្រជាជនភ្នំ ប្រទេសឡាវ ។ ទ្រឹស្តីរបស់គេគឺថា ព្រំដែននៃយៀកណាម គ្មានទីកំណត់ទេ ៖ អ្នកប្រវត្តិវិទូយួនម្នាក់ (រស់នៅប្រទេសបារាំង) បានសរសេរថា "*គេមិនគួរនិយាយ អំពី"ព្រំដែន"សំរាប់យៀកណាមទេ តែត្រូវហៅថាជា**ចលនាព្រំដែន** ដែលរុលទៅមុខ ដែលបានកើតមានជានិច្ច នៅក្នុងប្រវត្តិសាស្ត្រ នៃជនជាតិយៀកណាម*"[24] ។ យើងបានឃើញ នៅក្នុងឧទាហរណ៍កម្ពុជា នាពេលនេះទៀត ថា ទោះបីមានការកំរិត ដោយកិច្ចព្រមព្រៀងគ្នាក្តី ដីធ្លីជាប់និងព្រំដែន និងកោះតូច-ធំ របស់ខ្មែរ ត្រូវបានជនជាតិយួន នាំគ្នាទាំងហ្វូងៗ ចូលមកនៅកាន់កាប់ជាបន្តបន្ទាប់ ហើយពង្រីក"ទីលំហជីវិត"របស់វា ធំឡើងៗជាលំដាប់ ដោយរុញច្រានជនជាតិខ្មែរ ដោយមធ្យោបាយផ្សេងៗ ឲ្យចាកចេញពីទឹកដីនៃដូនតាខ្លួន។ "*ចលនា*"ដែនដីយួន ត្រូវតែរុលទៅមុខ ជាអចិន្ត្រៃយ៍ ។

ចំណែកឯ លោកហ៊ុន សែន វិញ ដែលស្រេកឃ្លានអំណាចជាខ្លាំង គាត់បានភ្ជាប់វាសនានយោបាយ របស់គាត់ ជាមួយនិងដំណើរវាតទីនិយមយួន តាំងពីដំបូងមក ។ នាថ្ងៃទី១៦ មករា ១៩៨២ នៅមុខសិស្ស នៃសាលាយោធាជើងគោក ហ៊ុន សែន បានធ្វើសំបថយ៉ាងខ្លាំងក្លាបំផុត ចំពោះ"*សាមគ្គីភាពកម្ពុជា-វៀតណាម ដែលជាអាវុធមួយដ៏វិសេស និងជាអាវុធតែមួយគត់ ដែលបានធ្វើឲ្យយើងរស់ នាពេលនេះ ហើយ នឹងរស់ក្នុង ឯករាជ្យ សន្តិភាព និងសុភមង្គល នាអនាគតកាល... (ហេតុនេះ) ការជំទាស់និងសាមគ្គីភាពហ្នឹង គឺជាការសម្លាប់ជីវិតរបស់ខ្លួនឯង ជាប្រាកដ* "[25] ។ ដោយជាប់និងប្រវាក់នៃសំបថនេះ ហ៊ុន សែន បានស៊ីញេ ហើយបានចេញមុខផ្ទាល់ខ្លួន ការពារកិច្ចព្រមព្រៀងទឹកដីនានា (និងកិច្ចព្រមព្រៀង បញ្ចូលពួក អាណានិគមយួន យ៉ាងសន្ធឹកសន្ធាប់ មក

---

[24] ក្នុងអត្ថបទ របស់ ង្វៀង ថៃ អាន់ ៖ NGUYÊN THÊ ANH, *Le Nam Tiên dans les textes vietnamiens*, in *Les Frontières du Vietnam. Histoire des Frontières de la Péninsule indochinoise*, sous la direction de P.B. Lafont, L'Harmattan, Paris, 1989 ; p.121

[25] ក្នុងសន្ទរកថា របស់ហ៊ុន សែន អំពី«សាមគ្គីភាពកម្ពុជា-វៀតណាម» ផ្សាយជាភាសាបារាំង ដោយបក្សប្រជាជនបដិវត្តិកម្ពុជា - ភ្នំពេញ ឆ្នាំ១៩៨២ ៖ HUN SEN, *La Solidarité Kampuchea-Vietnam*, Commission de Propagande et d'Education (du Parti), Phnom-Penh 1982, Texte français.


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

កម្ពុជា) តាមតែយួនចង់បាន ទោះបីមានការជំទាស់ ពីអ្នកដឹកនាំខ្លះនៃ ស.ប.ក.នោះក្តី (ឯកសារ *A21) ដោយជាន់ឈ្លីចោលទាំងអស់ នូវសិទ្ធិជាប្រវត្តិសាស្រ្ត នៃប្រទេសខ្លួន និង ការទាមទារយ៉ាងត្រឹមត្រូវ នៃរបបរដ្ឋខ្មែរមុនៗ ក្នុងរឿងទឹកដីជាមួយយួន ។ ជាបន្ទាប់មក កិច្ចព្រមព្រៀង សន្តិភាពនៃទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១ ដែលបានបញ្ជាក់ជាថ្មី នូវភាពពេញបរិបូណ៌ នៃ លក្ខន្តិកៈអន្តរជាតិនៃកម្ពុជា ហើយដែលយួននិងហ៊ុន សែន (ស.ប.ក./រដ្ឋកម្ពុជា) ជាហត្ថលេខីដែរ បានបង្គាប់យ៉ាងច្បាស់ ឲ្យ″កម្ពុជាលុបចោល រាល់កិច្ចព្រមព្រៀងដែលប៉ះពាល់ ដល់អធិបតេយ្យ ឯករាជ្យបូរណភាពទឹកដី និងភាពមិនអាចរំលោភបានលើទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិ នៃកម្ពុជា″ ។ ប៉ុន្តែ ហ៊ុន សែន ដែលរត់តាមជើងនៃក្រុងហាណូយ បានបំពានលើកិច្ចព្រមព្រៀង នៃទីក្រុងប៉ារីស ហើយបានបន្ត ការអនុវត្តិន៍នៃកិច្ចព្រមព្រៀងដ៏ចង្រៃ នៃសម័យយួនកាន់កាប់កម្ពុជា ដោយប្រើការភរភូត ការបន្លំបំភ័ន្ត ការធ្វើទុក្ខទោស និងការគំរាមកំហែង ទៅលើជនជាតិខ្មែរ និងមហាក្សត្ររបស់ខ្លួន ។ ហេតុនេះ នាថ្ងៃទី៩ សីហា ២០១២នេះទៀត ហ៊ុន សែន បានប្រកាសច្បាស់ជាថ្មី មិនព្រមការពារប្រយោជន៍នៃស្រុកខ្មែរ នៅចំពោះមុខយៀកណាម ទេ ។

ប៉ុន្តែ នៅក្នុងប្រវត្តិសាស្រ្តនៃប្រជាជាតិក្នុងលោក គ្មាននរណាអាចបំភ្លេចបាន នូវការបាត់បង់ នូវទឹកដី ដោយមិនសមហេតុផល ជាមួយនិងអំពើអយុត្តិធម៌ អំពើឃោរឃៅ សេចក្តីឈឺចាប់ សេចក្តីស្អប់គុំកួន ដែលប្រជាជនមួយ បានទទួលទេ ។ ប្រជាជនខ្មែរ ក៏ដូចប្រជាជនឯទៀតដែរ មិនអាចសុខចិត្តទទួលយក ព្រំដែនថ្មី នៃដីគោកនិងសមុទ្រ នៃកម្ពុជា ដែលអំណាចកាន់កាប់របស់យួន បានកំណត់ឲ្យ នាទសវត្សរ៍១៩៨០នោះទេ ។ យើងត្រូវតែរៀបចំព្រំដែនហ្នឹង ឲ្យបានត្រឹមត្រូវវិញ ដោយឈរលើសក្ខីកម្ម និងភស្តុតាងជាប្រវត្តិសាស្រ្ត នៃសិទ្ធិស្របច្បាប់របស់យើង ដែលជាគ្រឹះមូលដ្ឋាននៃមាតុភូមិខ្មែរ ក្នុងអតិតកាល ក្នុងបច្ចុប្បន្នកាល និងសំរាប់អនាគតកាល ទៅទៀត ។ យើងត្រូវខឹតខំរកនិងបង្ហាញ សក្ខីកម្មនិងឯកសារនៃសិទ្ធិជាប្រវត្តិសាស្រ្ត នៃទឹកដីជាតិយើង ហើយបន្តការតវ៉ាប្រឆាំងនិងអំណាចវាតទីនិយមយួន និងការរំលោភរបស់ពួកនេះ មកលើស្រុកយើង ។ ឧទាហរណ៍នាសព្វថ្ងៃនេះសោត គឺនៅក្នុងជម្លោះទល់និងប្រទេសចិន អំពីកោះផ្សេងៗ នៃ″សមុទ្រចិន″ ប្រទេសហ្វីលីពីនបានយកផែនទីនាវាចរណ៍ ដែលកើតមានពីឆ្នាំ១៥៩៨-១៨៩៨ ជាភស្តុតាងនៃ″កម្មសិទ្ធិ″របស់គេ លើកោះដែលគេកំពុងទាមទារ[26] ។ ប្រទេសយៀកណាម ក៏បានយកឯកសារ និង ផែនទីនានា ដែលកើតមានតាំងពីសតវត្សទី១៧ និងទី១៨ ព្រមទាំងឯកសារនៃសម័យបារាំង នៃសតវត្សទី

[26]ក្នុងអត្ថបទ សារព័ត៌មាន ៖ *Ancient maps support PH claim over Scarborough*, by Carlos Santamaria. Updated 06/27/2012 1:58 PM http://www.rappler.com/nation/7655-ancient-maps-support-ph-claim-over-scarborough


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com

១៩ និងទី២០ មកបង្ហាញនិងតវ៉ា អំពី"កម្មសិទ្ធិ"របស់គេដែរ[27]។ ជាពិសេសទៀត នៅចំពោះមុខចិន យៀកណាម (ដូចគ្នានិងហ្វីលីពីន) បានទាមទារឥតឈប់ឈរ ឲប្រទេសចិន"គោរពយ៉ាងម៉ត់ចត់" នូវភស្តុតាងជាប្រវត្តិសាស្ត្រ នៃអធិបតេយ្យភាពរបស់គេ លើកោះទាំងនោះ និងច្បាប់អន្តរជាតិ ស្តីអំពីសមុទ្រ ជាចាំបាច់ផង ។ បើសេចក្តីសំអាងរបស់យួន មានលក្ខណៈស្មោះត្រង់មែន រឿងជម្លោះអំពីកោះនៃសមុទ្រចិននេះ នឹងតម្រូវឲ្យយៀកណាមគិតជាថ្មី អំពីអាកប្បកិរិយាខ្លួន (ដែលត្រូវបានប្រទេសសាំងក្លាពួរ ថ្កោលទោស នៅអង្គការសហប្រជាជាតិហើយ) ចំពោះសិទ្ធិជាប្រវត្តិសាស្ត្រនៃកម្ពុជា លើដែនដីគោក និងលើកោះត្រល់ កោះក្រចកសេះ និងលើរបស់ហៅថា"តំបន់ទឹកប្រវត្តិសាស្ត្រ" របស់កម្ពុជាដែរ ដោយស្របពិតប្រាកដ តាមច្បាប់ អន្តរជាតិ ជាចាំបាច់ ។

បញ្ហាព្រំដែនកម្ពុជា-យៀកណាម ដែលបានផ្តល់សេចក្តីឈឺចាប់ឥតគណនា មិនទាន់បានដោះស្រាយចប់ទេ ហើយជនជាតិខ្មែរក៏មិនអាចបំភ្លេចបានឡើយ ដរាបណាយួន នៅតែមិនព្រមទទួលស្គាល់យ៉ាងម៉ត់ចត់ នូវសិទ្ធិស្របច្បាប់ និងស្របយុត្តិធម៌ របស់ខ្មែរ ក្នុងបញ្ហាជាអាយុជិវិតជាតិខ្មែរនេះទេ ។

៖៖៖៖៖៖៖៖៖

ទីក្រុងប៉ារីស ថ្ងៃទី១៧ ធ្នូ ២០១២

*ជ. គណកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក*

**ឌី ការ៉េត**

---

[27] ក្នុងអត្ថបទ សារព័ត៌មាន ៖ *A legal analysis in support of Viet Nam's position regarding the Paracel & Spratly Islands*, Monday, 28 May 2012 02:47 quanghung299 http://nghiencuubiendong.vn/en/publications/vietnamese-publications/698-a-legal-analysis-in-support-of-viet-nams-position-regarding-the-paracel-a-spratly-islands

-ក្នុងអត្ថបទ សារព័ត៌មាន ៖ *La souveraineté territoriale vue par les cartes*. La carte établie par l'évêque Jean-Louis Taberd en 1838. AVI, 07/08/2012 | 09:27:00 http://fr.vietnamplus.vn/Home/La-souverainete-territoriale-vue-par-les-cartes/20128/24429.vnplus


c/o M. SEAN Pengsè – 6 Allée des Frênes, 77420 Champs-sur-Marne, France – http://www.cfcambodge.org
Tél : +33 (0)1.64.68.70.83 – Email : pengse.sean@numericable.com - pengse.sean@gmail.com